ក្រសួងអប់រំ យុវជន និងកីឡា
MINISTRY OF EDUCATION YOUTH AND SPORTS
សាកលវិទ្យាល័យវ៉ាន់ដា
VANDA UNIVERSITY

# សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# ផលប៉ះពាល់ដុល្លារូបនីយកម្មមកលើសេដ្ឋកិច្ចកម្ពុជា

# THE IMPACT OF DOLLARIZATION ON THE CAMBODIAN ECONOMY

ជំនាញ គណនេយ្យ

រាជធានីភ្នំពេញ-ឆ្នាំ២០២៥
PHNOM PENH, 2025

ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

សាកលវិទ្យាល័យវ៉ាន់ដា

VANDA UNIVERSITY

# សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# ផលប៉ះពាល់ដុល្លារូបនីយកម្មមកលើសេដ្ឋកិច្ចកម្ពុជា

THE IMPACT OF DOLLARIZATION ON THE
CAMBODIAN ECONOMY

គ្រូណែនាំ៖ យឿន យ៉េង

ជំនាញ: គណនេយ្យ

រាជធានីភ្នំពេញ-ឆ្នាំ២០២៥

PHNOM PENH, 2025

**គណៈកម្មការត្រួតពិនិត្យសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាន់ទី២២**

**ប្រធានបទ៖ ផលប៉ះពាល់ដុល្លារូបនីយកម្មមកលើសេដ្ឋកិច្ចកម្ពុជា**

គណៈកម្មការវាយតម្លៃទី១

បេក្ខបណ្ឌិត មាស សំណាង

គ្រូណែនាំ

យឿន យ៉េង

គណៈកម្មការវាយតម្លៃទី៣

បេក្ខបណ្ឌិត ម៉ែម សុខហៀក

គណៈកម្មការវាយតម្លៃទី២

បេក្ខបណ្ឌិត យ៉ាក វុទ្ធី

ប្រធានគណៈកម្មការវាយតម្លៃ និងជានាយក
មជ្ឈមណ្ឌលស្រាវជ្រាវ

បណ្ឌិត សេង សំអឿន

អនុប្រធានគណៈកម្មការវាយតម្លៃ និងជានាយករង
មជ្ឈមណ្ឌលស្រាវជ្រាវ

បេក្ខបណ្ឌិត ស្រេង ផល្លា

**សាកលវិទ្យាធិការ**

**បណ្ឌិត ហេង វ៉ាន់ដា**

សាកលវិទ្យាធិការរងអចិន្ត្រៃយ៍

បណ្ឌិត ហ៊ួ គុជគន្ធលីនណា

# អារម្ភកថា

ក្រោយពីបានសិក្សាថ្នាក់បរិញ្ញាបត្រ ជំនាញគណនេយ្យនៅសាកលវិទ្យាល័យវ៉ាន់ដា អស់រយៈពេល៤ឆ្នាំរួចមកក្រុមយើងខ្ញុំបានទទួលនូវចំណេះដឹងជាច្រើន ពាក់ព័ន្ធនឹងមុខវិជ្ជាគណនេយ្យ ជាពិសេសក្រុមយើងខ្ញុំបានយល់ច្បាស់ថាជំនាញគណនេយ្យគឺជាជំនាញមួយមានសារៈសំខាន់ក្នុងការគ្រប់គ្រងទិន្នន័យប្រតិបត្តិការផ្សេងៗនៅក្នុងស្ថាប័នរដ្ឋក្តី ឯកជនក្តី ឬអង្គការក្រៅប្រទេស។ ដោយឡែកដើម្បីឱ្យ ការសិក្សា របស់និស្សិតកាន់តែមានគុណភាពខ្ពស់សាកលវិទ្យាល័យវ៉ាន់ដា បានបញ្ចូលនូវមុខជំនាញសំខាន់ៗដែលពាក់ព័ន្ធនឹងការងាររបស់គណនេយ្យតាមកម្មវិធីសិក្សាក្នុងឆ្នាំទីមួយ រហូតដល់ឆ្នាំសិក្សាទីបួន។

គ្រប់មុខវិជ្ជាទាំងអស់ សុទ្ធតែមានសារៈសំខាន់ក្នុងការត្រួសត្រាយផ្លូវនិស្សិតឱ្យយល់ច្បាស់ពីការអនុវត្តការងារគណនេយ្យ ពីការចាប់ផ្តើមរៀបចំរបាយការណ៍ ការអនុវត្ត ការបញ្ចប់ និងត្រួតពិនិត្យវាយតម្លៃព្រមទាំងផ្តល់អនុសាសន៍នៅក្នុងការងារគណនេយ្យ ដើម្បីពង្រឹងប្រសិទ្ធភាពគ្រប់គ្រងនៅក្នុងស្ថាប័នខ្លួន ក្នុងន័យឆ្លើយតបឱ្យបានល្អប្រសើរនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញ។ ដោយក្រុមយើងខ្ញុំសង្កេតឃើញថាកិច្ចការងារមួយនេះមានសារៈសំខាន់ខ្លាំង ស្របពេលនៃការសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្របានមកដល់ ទើបក្រុមយើងខ្ញុំសម្រេចចិត្តជ្រើសរើសនូវប្រធានបទមួយស្តីពី «ផលប៉ះពាល់ដុល្លារូបនីយកម្មមកលើសេដ្ឋកិច្ចកម្ពុជា» យកមកសិក្សាស្រាវជ្រាវនិងចងក្រងក្នុងគោលបំណងឱ្យអ្នកស្រាវជ្រាវទាំងអស់យល់កាន់តែស៊ីជម្រៅពីការរៀបចំសារណា និងប្រសិទ្ធភាពនៃការគ្រប់គ្រងទិន្នន័យ។ ក្រុមយើងខ្ញុំសង្ឃឹមថាការរៀបចំសារណានេះ នឹងចូលរួមចំណែកក្នុងការស្រាវ ជ្រាវដទៃទៀតដែលមានបំណងសិក្សាស្វែងយល់ពីកិច្ចការនេះ។

ជាទីបញ្ចប់ក្រុមយើងខ្ញុំ សូមមេត្តាខន្តី អភ័យទោស ពីសំណាក់លោកគ្រូ អ្នកគ្រូ រៀមច្បង និងអ្នកអានទាំងអស់ នូវរាល់កំហុសឆ្គងដែលកើតមានដោយអចេតនា នៅក្នុងសារណានេះ ហើយក្រុមយើងខ្ញុំរីករាយនឹងទទួលយករាល់ការរិះគន់ក្នុងន័យស្ថាបនា ដើម្បីឱ្យការរៀបចំលើកក្រោយទៀតមានភាព កាន់តែល្អប្រសើរ។

# រចនាសម្ព័ន្ធក្រុម



**ជា សុខហៀង**

B22/2406



**ចោង សុវី**

B22/1213



**លីម ម៉ាលីគួង**

B22/2018



**ឡុង ម៉ីម៉ី**

B22/2369



**ឈាន សុខឈេង**

B22/1212

# សេចក្តីថ្លែងអំណរគុណ

ក្រុមយើងខ្ញុំជានិស្សិតនៃសាកលវិទ្យាល័យវ៉ាន់ដា ថ្នាក់បរិញ្ញាបត្រ ជំនាន់ទី២២ ជំនាញគណនេយ្យ ។

**សូមសម្តែងនូវការគោរពដឹងគុណ និងថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះ**

ក្រុមគ្រួសារដែលបានឧបត្ថម្ភ គាំទ្រ ទាំងសម្ភារៈ ថវិកា និងស្មារតី ជំរុញលើកទឹកចិត្ត ដល់ក្រុមយើងខ្ញុំ ក្នុងការសិក្សារៀនសូត្រ ដើម្បីទទួលបានចំណេះដឹងរហូតមកដល់សព្វថ្ងៃនេះ។ ក្នុងនោះក្រុមយើងខ្ញុំសូមសម្តែងនូវការគោរព និងកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុត ដល់អ្នកមានគុណ ដែលបានផ្តល់កំណើតដល់នាងខ្ញុំគ្រប់រូប និងសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ដល់សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ ទាំងអស់ដែលបានបណ្តុះបណ្តាលក្រុមយើងខ្ញុំនាពេលកន្លងមក។

ក្រុមយើងខ្ញុំ សូមសម្តែងនូវការគោរពដឹងគុណដ៏ជ្រាលជ្រៅ ដល់ឯកឧត្តមបណ្ឌិត ហេង វ៉ាន់ដា សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យ វ៉ាន់ដា ដែលបានផ្តល់ទីកន្លែងបណ្តុះបណ្តាល ព្រមទាំងផ្តល់បទពិសោធន៍យ៉ាងច្រើនដល់ក្រុមយើងខ្ញុំ។

សូមគោរពថ្លែងអំណរគុណចំពោះលោកគ្រូ ឃឿន យ៉េង ជាលោកគ្រូណែនាំដោយបានជួយជ្រោមជ្រែងបង្ហាត់បង្ហាញសព្វបែបយ៉ាងដើម្បីជួយដល់ក្រុមយើងខ្ញុំបញ្ចប់កិច្ចការសារណានេះជាស្ថាពរ។

សូមគោរពថ្លែងអំណរគុណដល់សាស្ត្រាចារ្យ លោកគ្រូអ្នកគ្រូ និងបុគ្គលិកនៃសាកលវិទ្យាល័យវ៉ាន់ដាទាំងអស់ដែលបានខិតខំប្រឹងប្រែងក្នុងការបង្ហាត់បង្ហាញ លើកទឹកចិត្ត អនុគ្រោះដល់ក្រុមយើងខ្ញុំ រហូតធ្វើឱ្យការសិក្សាបានបញ្ចប់ និងទទួលបានជោគជ័យគួរជាទីមោទនៈ។

ឆ្លៀតក្នុងឱកាសនេះដែរ ក្រុមយើងខ្ញុំសូមប្រសិទ្ធពរជ័យជូនដល់បុគ្គលទាំងអស់ខាងលើឱ្យបានជួបតែពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អំណះអំណាង

ក្រុមនាងខ្ញុំ ជានិស្សិតបរិញ្ញាបត្រ ជំនាញគណនេយ្យនៃសាកលវិទ្យាល័យ វ៉ាន់ដា ជំនាន់ទី២២៖ សូមធានាអះអាងថា ខ្លឹមសារសារណាក្រោមប្រធានបទ “ផលប៉ះពាល់ដុល្លារូបនីយកម្មមកលើសេដ្ឋកិច្ចកម្ពុជា” នេះគឺជាស្នាដៃរបស់ក្រុមនាងខ្ញុំ ដោយគ្មានការពាក់ព័ន្ធនឹងរបាយការណ៍ស្រាវជ្រាវរបស់អ្នកផ្សេងឡើយ។ ទិន្នន័យ និងលទ្ធផលនៃការស្រាវជ្រាវ ដែលលើកឡើងនេះ ជាអត្ថបទស្រាវជ្រាវថ្មីសុទ្ធសាធ ដែលពុំធ្លាប់មានជនណាម្នាក់យកទៅប្រើប្រាស់ក្នុងការស្រាវជ្រាវពីមុនឡើយ។

ថ្ងៃ.ពុធ..៨កើត.ខែកត្តិក.ឆ្នាំម្សាញ់ សប្តស័ក ព.ស២៥៦៩

ថ្ងៃទី២៩ខែតុលាឆ្នាំ២០២៥

**ហត្ថលេខាតំណាងក្រុម**



ជា សុខហៀង

# សេចក្តីសង្ខេបនៃការស្រាវជ្រាវ

នាពេលបច្ចុប្បន្ននេះ ពិភពលោកទាំងមូលស្ទើរតែគ្រប់ប្រទេសទាំងអស់ បានអនុវត្តនូវប្រព័ន្ធសេដ្ឋកិច្ចបែប ទីផ្សារសេរី នៅក្នុងប្រព័ន្ធនេះគេបានកំណត់យករូបិយវត្ថុ ជាកត្តានាំមុខនៅក្នុងការធ្វើពាណិជ្ជកម្មជាលក្ខណៈជាតិនិងអន្តជាតិសុទ្ធតែយករូបិយវត្ថុជាកត្តាសំខាន់សម្រាប់ ជាមធ្យោបាយដោះដូរនិងទូទាត់។ ទោះបីជាយ៉ាងណា ក៏ដោយ នៅតាមបណ្តាប្រទេសភាគច្រើននៅទូទាំងពិភពលោកមានតែរូបិយប័ណ្ណជាតិរបស់គេប៉ុណ្ណោះ ដែល ចរាចរណ៍នៅលើទីផ្សារ។ អ្នកដែលធ្លាប់ធ្វើដំណើរទៅក្រៅប្រទេសប្រាកដជានិងបានដឹងហើយថាដើម្បីធ្វើការទិញ ដូរទំនិញ នៅក្នុងប្រទេសណាមួយបានគេចាំបាច់ត្រូវធ្វើការប្តូររូបិយប័ណ្ណជាតិរបស់ប្រទេសពួកគេអោយដូចទៅ និងប្រទេសដែលគេកំពុងធ្វើការជួញដូរ ឬមានបំណងក្នុងការជួញដូរ ឬមានការធ្វើដំណើរទៅកាន់ប្រទេសនោះ ជាមុនសិន។ យោងតាមប្រធានបទខាងលើ ឥទ្ធិពលនៃដុល្លារូបនីយកម្មមកលើសេដ្ឋកិច្ចកម្ពុជា″យើងក៏បានលើកនិយមន័យ មកបកស្រាយគឺ-ដុល្លារូបនីយកម្ម។

“ដុល្លារូបនីយកម្ម” (Dollarization) គឺជាការចាប់យករូបិយប័ណ្ណរបស់បរទេសណាមួយ សម្រាប់ធ្វើការទូទាត់ស្របច្បាប់នៅក្នុងប្រតិបត្តិការរូបិយវត្ថុ។ ដុល្លារូបនីយកម្មក្រៅផ្លូវការមានន័យថា ប្រជាពលរដ្ឋចូលចិត្តរូបិយប័ណ្ណបរទេសសម្រាប់ប្រតិបត្តិការមួយចំនួន ទោះបីជាវាមិនអាចជាការទូទាត់មានលក្ខណៈផ្លូវការក៏ដោយ។ ដុល្លារូបនីយកម្មជាផ្លូវការមានន័យថា រូបិយប័ណ្ណបរទេសក្លាយជាការទូទាត់ដ៏ពេញចិត្តនៅក្នុងប្រទេស ខណៈរូបិយប័ណ្ណក្នុងស្រុកក៏អាចទទួលយកផងដែរ។ មូលហេតុចម្បងសម្រាប់ដុល្លារូបនីយកម្ម គឺដើម្បីជំនួសរូបិយប័ណ្ណដែលមានស្ថិរភាពសម្រាប់រូបិយប័ណ្ណមិនមានស្ថេរភាពមួយ។ ជាញឹកញាប់ប្រាក់ដុល្លារូបនីយកម្មពាក់ព័ន្ធនឹងប្រាក់ដុល្លារសហរដ្ឋអាមេរិក ទោះបីជាវាអាចត្រូវបានផ្អែកលើរូបិយប័ណ្ណផ្សេងទៀតដូចជាប្រាក់អឺរ៉ូជាដើម ។ គុណប្រយោជន៍ គឺនៅត្រង់ថានៅក្នុងពេលដែលសាធារណជនមិនមានទំនុកចិត្តលើលុយរៀលមាន ការអនុញ្ញាតឱ្យប្រើប្រាស់ដុល្លារអាចបញ្ចៀសកុំឱ្យកម្ពុជាត្រូវប្រឈមមុខ នឹងចលនាហូរចេញមូលធនទៅក្រៅប្រទេស ដោយសារតែមិនមានទំនុកចិត្តលើប្រាក់រៀល អ្នកមានប្រាក់មិនចង់រក្សាទុកប្រាក់រៀលច្រើនហើយនាំគ្នាស្វះស្វែងរកកន្លែងទុកប្រាក់ជាដុល្លារ ឬប្រាក់បរទេសផ្សេងទៀត ដែលគេគិតថាមានហានិភ័យតិចជាង។ ប្រសិនបើនៅកម្ពុជាដុល្លារមិនត្រូវបានអនុញ្ញាតឱ្យធ្វើចរាចរណ៍យ៉ាងទូលំទូលាយ ដូចសព្វថ្ងៃនេះទេ ដើម្បីអាចទុកប្រាក់ជាដុល្លារគេប្រាកដជាត្រូវយកប្រាក់ទៅទុកនៅក្នុងធនាគារឯក្រៅប្រទេស ហើយមូលធន ដែលជាកត្តាសំខាន់សម្រាប់កំណើនសេដ្ឋកិច្ចជាតិនិងត្រូវហូរចេញទៅក្រៅប្រទេស។ តាមរយៈអត្ថបទខាងលើក្រុមយើងខ្ញុំយល់ឃើញថាការ ប្រើប្រាស់ប្រាក់ដុល្លារពិតជាមានភាពងាយស្រួលជាងការប្រើប្រាស់ប្រាក់រៀល ដោយសារប្រាក់ដុល្លារជារូបិយប័ណ្ណដែលចរន្តបានគ្រប់បណ្តាប្រទេសទូរទាំងសកលលោក ម្យ៉ាងទៀតដុល្លារូបនីយកម្មក៏បានរួមចំណែកដល់ការរីកចម្រើនសកម្មភាពសេដ្ឋកិច្ចកម្ពុជាគួរឱ្យកត់សម្គាល់ដោយ មានការវិនិយោគពីជនបរទេសផ្ទាល់ការនាំចេញការនាំចូលបានយ៉ាងឆាប់រហ័សទៅក្នុងនិងតំបន់ពិភពលោក។

# មាតិកា

ទំព័រ

អារម្ភកថា ................................................ i
រចនាសម្ព័ន្ធ ................................................ ii
សេចក្តីថ្លែងអំណរគុណ ................................................ iii
អំណះអំណាង ................................................ iv
សេចក្តីសង្ខេបនៃការស្រាវជ្រាវ ................................................ v
មាតិកា ................................................ vi

## ជំពូកទី១
## សេចក្តីផ្តើម

១.១ លំនាំបញ្ហានៃការស្រាវជ្រាវ ................................................ ១
១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ ................................................ ១
១.៣ គោលបំណងនៃការស្រាវជ្រាវ ................................................ ២
១.៤ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ................................................ ២
    ១.៤.១ ទំហំ និងដែនកំណត់ ................................................ ២
    ១.៤.២ វិសាលភាព ................................................ ២
១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ ................................................ ៣
១.៦ សារៈសំខាន់នៃការស្រាវជ្រាវ ................................................ ៣
១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ................................................ ៤

## ជំពូកទី២
## ផលប៉ះពាល់ដុល្លារូបនីយកម្មមកលើសេដ្ឋកិច្ច

២.១ លក្ខណៈទូទៅនៃដុល្លារូបនីយកម្ម ................................................ ៥
    ២.១.១ និយមន័យដុល្លារូបនីយកម្ម ................................................ ៥
    ២.១.២ ប្រវត្តិនៃដុល្លារូបនីយកម្ម ................................................ ៥
២.២ កត្តាដែលនាំឱ្យមានដុល្លារូបនីយកម្មមកលើសេដ្ឋកិច្ចកម្ពុជា ................................................ ៦
    ២.២.១ និយមន័យសេដ្ឋកិច្ច ................................................ ៦
    ២.២.២ ប្រវត្តិសេដ្ឋកិច្ច ................................................ ៧
    ២.២.៣ ទ្រឹស្តីសេដ្ឋកិច្ច ................................................ ៨
២.៣ ផលប៉ះពាល់ដុល្លារូបនីយកម្មមកលើសេដ្ឋកិច្ចកម្ពុជា ................................................ ៨
    ២.៣.១ និយមន័យដុល្លារ ................................................ ៨
    ២.៣.២ ប្រវត្តិដុល្លារ ................................................ ៩
    ២.៣.៣ ប្រភេទដុល្លារ ................................................ ១០

## ជំពូកទី៣
## ផលប៉ះពាល់ដុល្លារូបនីយកម្មលើសេដ្ឋកិច្ចកម្ពុជា

៣.១ ស្ថានភាពទូទៅរបស់នៃដុល្លារូបនីយកម្មលើសេដ្ឋកិច្ចកម្ពុជា ............ ១១
៣.១.១ ប្រវត្តិនៃធនាគារជាតិ ............ ១១
៣.១.២ ចក្ខុវិស័យ ធនាគារជាតិ ............ ១១
ក. ចក្ខុវិស័យ ............ ១១
ខ. បេសកកម្ម ............ ១២
គ. គោលដៅ ............ ១២
៣.១.៣ រចនាសម្ព័ន្ធគ្រប់គ្រងតួនាទី និងភារកិច្ចរបស់ ធនាគារជាតិ ............ ១៥
៣.២ កត្តាដែលនាំឱ្យមានដុល្លារូបនីយកម្មមកលើសេដ្ឋកិច្ចកម្ពុជា ............ ១៦
៣.២.១ ស្ថានភាពសន្តិសុខក្នុងប្រទេសនិងការបាត់បង់ទំនុកចិត្តពីសាធារណជនទៅលើរូបិយប័ណ្ណជាតិ "រៀល" ............ ១៧
៣.២.២ បញ្ហាសេដ្ឋកិច្ច និងការធ្លាក់ចុះនៃលុយរៀល ............ ១៩
៣.២.៣ វត្តមាននៃការវិនិយោគពីក្រុមហ៊ុននិងអង្គការក្រៅប្រទេស ............ ២០
៣.៣ ផលប៉ះពាល់ដុល្លារូបនីយកម្មមកលើសេដ្ឋកិច្ចកម្ពុជា ............ ២០
៣.៣.១ គុណសម្បត្តិ ............ ២១
៣.៣.២ គុណវិបត្តិ ............ ២៣

## ជំពូកទី៤
## ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

៤.១ ការវិភាគលើចំណុចខ្លាំង ............ ២៤
៤.២ ការវិភាគលើចំណុចខ្សោយ ............ ២៥

## ជំពូកទី៥
## សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

៥.១ សេចក្តីសន្និដ្ឋាន ............ ២៧
៥.២ ការផ្តល់អនុសាសន៍ ............ ២៨

**ឯកសារយោង**

**ឧបសម្ព័ន**

# ជំពូកទី១
# សេចក្តីផ្តើម

# ជំពូកទី១
# សេចក្តីផ្តើម

## ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

នៅក្នុងបណ្តាសេដ្ឋកិច្ចរបស់ប្រទេសនានា រូបិយប័ណ្ណជាតិនៃប្រទេសមួយមានតួនាទីសំខាន់ក្នុងការទ្រទ្រង់ប្រព័ន្ធហិរញ្ញវត្ថុ និងការអភិវឌ្ឍសេដ្ឋកិច្ច។ ប្រាក់រៀល ប្រាក់ដុង ប្រាក់ដុល្លារ ប្រាក់អឺរ៉ូ និងប្រាក់របស់ប្រទេសដទៃទៀត ។ រូបិយប័ណ្ណទាំងអស់នោះត្រូវបានគេប្រើជាវត្ថុសម្រាប់ជួញដូរ និងដោះដូរទំនិញ ឬសេវានៅក្នុងទីផ្សារសេដ្ឋកិច្ចរបស់ប្រទេសនីមួយៗ។ ទោះបីជាយ៉ាងនេះ នៅក្នុងប្រទេសកម្ពុជា រូបិយប័ណ្ណដុល្លារអាមេរិកត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយជាច្រើនទសវត្សរ៍មកហើយ។ ស្ថានភាពនេះត្រូវបានហៅថា"ដុល្លារូបនីយកម្ម" ដែលមានន័យថា ប្រទេសមួយអាស្រ័យលើរូបិយប័ណ្ណបរទេសក្នុងការប្រតិបត្តិការទូទៅ។ ដុល្លារូបនីយកម្មនេះមានអត្ថប្រយោជន៍ និងបញ្ហាផ្សេងៗដែលមានឥទ្ធិពលលើសេដ្ឋកិច្ចជាតិ។

ដុល្លារូបនីយកម្មបានកើតមាននៅកម្ពុជា តាំងពីចុងសម័យសង្គ្រាមក្នុងទសវត្សរ៍ទី ៨០និង៩០។ក្រោយពីរបបខ្មែរក្រហម និងការបំផ្លិចបំផ្លាញប្រព័ន្ធហិរញ្ញវត្ថុជាតិ ប្រជាជនខ្មែរបានបាត់បង់ទំនុកចិត្តលើប្រាក់រៀលហើយចាប់ផ្តើមប្រើប្រាស់ដុល្លារជារូបិយប័ណ្ណសំខាន់ក្នុងប្រតិបត្តិការប្រចាំថ្ងៃ។ បច្ចុប្បន្នដុល្លារបានក្លាយជារូបិយប័ណ្ណមួយដែលប្រើប្រាស់យ៉ាងទូលំទូលាយក្នុងប្រព័ន្ធធនាគារ ការវិនិយោគ និងប្រតិបត្តិការពាណិជ្ជកម្ម។ ជាក់ស្តែងសេដ្ឋកិច្ចកម្ពុជាបានទទួលអត្ថប្រយោជន៍មួយចំនួនអំពីដុល្លារូបនីយកម្ម ដោយសារតែដុល្លារអាមេរិកមានតម្លៃស្ថិតស្ថេរ និងទទួលស្គាល់ទូទាំងពិភពលោក។

ដោយសារតែដុល្លារមិនងាយកើតការរញ្ជួយតម្លៃការប្រើប្រាស់វាបានជួយទប់ស្កាត់ការវាយតម្លៃរូបិយប័ណ្ណ និងការលំបាកក្នុងការជួញដូរ។ ហើយការប្រើប្រាស់ដុល្លារបានបន្ទូសភាពអភ័ព្វក្នុងប្រព័ន្ធហិរញ្ញវត្ថុ វាបានបង្កើនការចាក់វិនិយោគពីបណ្តាប្រទេសបរទេស និងធ្វើឱ្យទីផ្សារមានភាពរលូន។ដុល្លារជារូបិយប័ណ្ណអន្តរជាតិ វាជួយឱ្យកម្ពុជាមានភាពងាយស្រួលក្នុងការនាំចេញ និងនាំចូលដោយគ្មានការបារម្ភអំពីការប្តូរប្រាក់ជាតិទៅរូបិយប័ណ្ណបរទេស។ទោះបីជាមានអត្ថប្រយោជន៍ច្រើនក៏ដោយការអាស្រ័យលើដុល្លារមានគ្រោះថ្នាក់ដល់សេដ្ឋកិច្ចជាតិក្នុងរយៈពេលវែង។ ប្រទេសដែលប្រើប្រាស់ដុល្លារខ្លាំងពេកនឹងបាត់បង់សិទ្ធិក្នុងការគ្រប់គ្រងអត្រាការប្រាក់ និងការបង្កើតប្រាក់ក្នុងប្រព័ន្ធធនាគារ។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

នៅតាមបណ្តាលប្រទេសនីមួយៗមានភាពល្អប្រសើរពិតជាមានសារៈសំខាន់ ក្នុងការចូលរួមចំណែកធ្វើអោយប្រទេសរបស់ខ្លួនមានភាពរីកចម្រើននិងអភិវឌ្ឍលូតលាស់ទៅមុខយ៉ាងឆាប់រហ័ស។ នៅក្នុងប្រទេសកម្ពុជាគឺជាប្រទេសដែលកំពុងអភិវឌ្ឍលើគ្រប់វិស័យបន្ទាប់ពីជួបប្រទះនិងសង្គ្រាមអស់រយៈពេលជាច្រើនឆ្នាំមកកម្ពុជាមានការពឹងផ្អែកយ៉ាងខ្លាំងពីសំណាក់អ្នកវិនិយោគក្រៅប្រទេសដើម្បីអភិវឌ្ឍប្រទេស ដែលជាហេតុធ្វើឱ្យមានប្រាក់ដុល្លារហូរចូលមកក្នុងប្រទេសកម្ពុជាកាន់តែច្រើន ភាគច្រើនការដោះដូរទំនិញគឺប្រើប្រាស់ប្រាក់ដុល្លារ ដុល្លារកាន់តែថ្លៃនិងជាតម្រូវការរបស់អ្នកវិនិយោគ។ ដោយសារតែបែបបនេះហើយទើបប្រាក់រៀលដែលជារូបិយវត្ថុជាតិបែរជាមិនសូវមានតម្លៃ មានន័យថាប្រាក់រៀលកាន់តែចុះថោក ធ្វើឱ្យអត្រាប្តូរប្រាក់រៀលមានការ

ប្រែប្រួលមិនទៀងទាត់។ ដោយសារមូលហេតុខាងលើទើបក្រុមនាងខ្ញុំមានសំណួរមួយចំនួនបានចោទសួរឡើងដូចខាងក្រោម៖

១. តើមានកត្តាអ្វីខ្លះដែលជំរុញឱ្យមានដុល្លាររូបនីយកម្មនៅក្នុងសេដ្ឋកិច្ចកម្ពុជា ?

២.តើការកើនឡើងនៃដុល្លារូបនីយកម្មមានផលប៉ះពាល់អ្វីខ្លះដល់សេដ្ឋកិច្ចកម្ពុជា ?

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

ប្រធានបទដែលក្រុមសារណាយើងខ្ញុំលើកយកមើលធ្វើ បទបង្ហាញនេះ គឺមានគោលបំណងលើកមកសិក្សាយល់ដឹងពីចំណុចសំខាន់ៗដូចខាងក្រោម៖

- ដំណើរការនៃការហូរចូលរូបិយវត្ថុដុល្លារនៅក្នុងកម្ពុជា
- យល់ដឹងអំពីការប្រើប្រាស់ប្រាក់ដុល្លាររបស់ប្រជាជនកម្ពុជា
- ស្វែងយល់អំពីគុណសម្បត្តិនិងគុណវិបត្តិនៃការប្រើប្រាស់ប្រាក់ដុល្លារក្នុងសេដ្ឋកិច្ចកម្ពុជា
- ផលប៉ះពាល់ពីការហូរចូលរូបិយវត្ថុបរទេសមកលើកម្ពុជា
- គោលនយោបាយរូបយវត្ថុ
- និងដើម្បីសិក្សាស្រាវជ្រាវយកបទពិសោធអំពីឥទ្ធិពលនៃដុល្លារូបនីយកម្មលើសេដ្ឋកិច្ចកម្ពុជា។

## ១.៤ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

### ១.៤.១ ទំហំ និងដែនកំណត់

ដើម្បីឱ្យការសិក្សាស្វែងយល់និងស្រាវជ្រាវទៅលើប្រធានបទ ឥទ្ធិពលនៃដុល្លារូបនីយកម្មមកលើសេដ្ឋកិច្ចកម្ពុជាកាន់តែស៊ីជម្រៅថែមទៀត និងសម្រេចគោលដៅស្របតាមពេលវេលាដែលបានកំណត់ជាបឋមក្រុមនាងខ្ញុំបានកំណត់នូវ ទំហំ ដែនកំណត់នៃការស្រាវជ្រាវនេះឡើង។

ការស្រាវជ្រាវនេះធ្វើឡើងផ្តោតសំខាន់ទៅលើឥទ្ធិពលនៃដុល្លារូបនីយកម្មមកលើសេដ្ឋកិច្ចកម្ពុជា បានជ្រើសរើសយកធនាគារជាតិជាគោលដៅធំបំផុតដើម្បីជាស្ពានឈានទៅរកគោលដៅនៃការស្រាវជ្រាវ និង បំពេញតម្រូវការឱ្យកាន់តែមានអត្ថន័យពេញលេញនិងកាន់តែទូលំទូលាយ។ អាសយដ្ឋាន : អគារលេខ២៧៣ ផ្លូវលេខ១១០ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ ក្រុងភ្នំពេញ។

### ១.៤.២ វិសាលភាព

ដោយសារតែពេលវេលានៃការស្រាវជ្រាវពីប្រធានបទខាងលើនេះមានកំណត់ដូច្នេះទើបក្រុមនាងខ្ញុំសម្រេចកំណត់យកឯកសារ និងទិន្នន័យពាក់ព័ន្ធនានាដែលផ្តោតទៅលើដុល្លារូបនីយកម្មមកលើសេដ្ឋកិច្ចកម្ពុជានៅក្នុងចន្លោះឆ្នាំ២០២៣ ដល់ ២០២៤ ដើម្បីយកមកធ្វើការសិក្សាស្រាវជ្រាវតែប៉ុណ្ណោះ។

## ១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ

ក្នុងការសិក្សាស្រាវជ្រាវនេះក្រុមនាងខ្ញុំបានជ្រើសរើសយកវិធីសាស្ត្រដែលប្រើប្រាស់ក្នុងការសិក្សាស្រាវជ្រាវគឺជាការសិក្សាស្រាវជ្រាវបែបគុណវុឌ្ឍិជាតិ (National qualifications) ដោយផ្តោតសំខាន់ទៅលើទិន្នន័យបន្ទាប់បន្សំ (Secondary Data) គឺជាទិន្នន័យមួយដែលមានឯកសារច្បាស់លាស់។

សម្រាប់សំណួរទី១៖ ពាក់ព័ន្ធទៅនឹងការសិក្សាស្រាវជ្រាវនេះការដកស្រង់ទិន្នន័យដែលមានស្រាប់ពីគេហទំព័រដូចជាៈ Cambonomic Times (ផ្តោតទៅលើដុល្លារូបនីយកម្ម) The dollarization is meaning(តើអ្វី

ជាដុល្លារូបនីយកម្ម)The dollarization history is meaning(ប្រវត្តិដុល្លារូបនីយកម្ម)។ និងរបាយការណ៍ព្រម ទាំងការស្រាវជ្រាវ ដែរបានបោះពុម្ពឯកសារដោយធនាគារជាតិនៃកម្ពុជា សៀវភៅសេដ្ឋកិច្ចផ្សេងៗទៀតដែល បានបោះពុម្ពជាភាសារអង់គ្លេសដោយសាស្ត្រាចារ្យល្បីល្បាញ ឯកសារពី Internet សៀវភៅសារណារបស់ សិស្សច្បងនិងនិស្សិតជំនាន់មុនៗ(ការប្រកួតស្នាដៃស្រាវជ្រាវស្តីពីដុល្លារូបនីយកម្មមានផលប៉ះពាល់អ្វីខ្លះមក លើសេដ្ឋកិច្ចកម្ពុជា)។

សម្រាប់សំណួរស្រាវជ្រាវទី២៖ ពាក់ព័ន្ធទៅនិងកាសិក្សាស្រាវជ្រាវនេះ គឺប្រមូលទិន្ន័យតាមបែបគុណ វិស័យធ្វើឡើងតាមរយៈការដកស្រង់ទិន្ន័យដែលមានស្រាប់ពីគេហទំព័រដូចជាៈ What is the Economic (តើ សេដ្ឋកិច្ចជាអ្វី) The Economic History (ប្រវត្តិសេដ្ឋកិច្ច) What is the Dollar (តើអ្វីជាដុល្លារ) The dollar History (ប្រវត្តិដុល្លារ)ឯកសារដែលពាក់ព័ន្ធមួយចំនួនទៀតនៅក្នុងបណ្ណាល័យវិទ្យាស្ថានវ៉ាន់ដា បណ្ណាល័យ ផ្សេងៗទៀតថែមទាំងការសុំមតិយោបល់ ការណែនាំអំពីលោកគ្រូដឹកនាំ និងបូករួមគំនិតឆ្នៃប្រឌិតរបស់ក្រុម នាងខ្ញុំផ្ទាល់។

## ១.៦ សារៈសំខាន់នៃការស្រាវជ្រាវ

អត្ថប្រយោជន៍នៃការសិក្សាស្រាវជ្រាវនេះបានធ្វើអោយ ក្រុមនាងខ្ញុំផ្ទាល់ក៏ដូចជាសិស្សប្អូនជំនាន់ ក្រោយ និងប្រជាជនកម្ពុជាទាំងមូលបានយល់ដឹង នៃការហូរចូលនិងការចរាចរដុល្លាររូបនីយកម្មមកលើសេដ្ឋ កិច្ចកម្ពុជាដូចខាងក្រោម៖

❖ **ចំពោះអ្នកស្រាវជ្រាវ**

- ការស្រាវជ្រាវអាចជួយជំរុញសកម្មភាពសិក្សា និងការអប់រំសេដ្ឋកិច្ច
- យល់ដឹងអំពីការប្រើប្រាស់ប្រាក់ដុល្លាររបស់ប្រជាជនកម្ពុជា
- និងសម្រាប់ការសិក្សាស្រាវជ្រាវស្វែងយល់បន្ថែមយកជាបទពិសោធ៍អំពីឥទ្ធិពលនៃដុល្លារ រូបនីយកម្ម មកលើសេដ្ឋកិច្ចកម្ពុជា។
- បានបណ្តុះគំនិតស្រឡាញ់រូបិយវត្ថុជាតិខ្មែរ ដែលឆ្លុះបញ្ចាំងពីវប្បធម៌ និងអត្តសញ្ញាណជាតិ

❖ **ចំពោះស្ថាប័ន**

- វាក៏អាចជួយក្នុងការពង្រឹងអំណាចទូទាត់ និងប្រើប្រាស់ធនាគារជាតិនៅក្នុងការជួញដូរ
- ជាគំនិតមួយសម្រាប់អ្នកធ្វើគោលនយោបាយរូបិយវត្ថុក្នុងការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល

❖ **ចំពោះសង្គម**

- អាចបង្កើតការយកចិត្តទុកដាក់ពីគម្រោងអន្តរជាតិនានាដើម្បីគាំទ្រដល់សេដ្ឋកិច្ចកម្ពុជា
- យល់ដឹងពីការកាត់បន្ថយហានិភ័យប្តូរប្រាក់ និងការធ្វើព្រឹទ្ធិកម្ម (Speculation) ពីការធ្វើឱ្យអត្រាប្តូរ ប្រាក់ប្រែប្រួល
- ការស្រាវជ្រាវអំពីផលប៉ះពាល់នៃដុល្លារូបនីយកម្ម អ្នករៀបចំគោលនយោបាយសេដ្ឋកិច្ចអាចកំណត់ វិធីសាស្រ្តប្រើប្រាស់ប្រាក់រដ្ឋ និងការត្រួតពិនិត្យចំណូលចំណាយជាមួយឧបករណ៍រូបនីយកម្មផ្សេងៗ
- ធ្វើឱ្យកូនខ្មែរយល់ដឹងនិងលើកស្ទួយប្រាក់រៀលឡើងវិញ
- យល់ដឹងពីភាពខ្លាំងខ្សោយរបស់ក្រដាសប្រាក់ដុល្លារ

- យល់ដឹងអំពីអត្រាប្តូរប្រាក់នៅកម្ពុជា
- ជាពិសេសក្នុងការរៀនពីផលប៉ះពាល់នៃរូបនីយកម្មដល់បរិស្ថានសេដ្ឋកិច្ចក្នុងរយៈពេលវែង
- ស្វែងយល់ពីការទប់ស្កាត់ប្រាក់ដុល្លាររូបនីយកម្មហូរចូលមកកម្ពុជា

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ធ្វើឡើងដើម្បីស្វែងយល់ឱ្យដឹងកាន់តែច្បាស់នូវចំណុចនីមួយៗ និងការរាប់បញ្ចូលចំណុចដែលមានសេចក្តីផ្តើមនៃការស្រាវជ្រាវ គោលបំណង វិធីសាស្ត្រ សារៈសំខាន់នៃការស្រាវជ្រាវ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ សេចក្តីសន្និដ្ឋាន អនុសាសន៍ និងមានចំណុចជាច្រើនទៀត។ ក្រោយពីបានសិក្សាស្រាវជ្រាវរួចមក ក្រុមយើងខ្ញុំក៏បានបែងចែកជាប្រាំជំពូកដែលបានរៀបរាប់ដូចខាងក្រោម៖

**ជំពូកទី១៖** (សេចក្តីផ្តើម) បរិយាយសង្ខេបពីលំនាំបញ្ហា គោលបំណងមូលហេតុនៃការស្រាវជ្រាវ ចំណោទបញ្ហា ហេតុផលមួយចំនួនដែលបង្កើតឱ្យមានការសិក្សាស្រាវជ្រាវ។

**ជំពូកទី២៖** (រំលឹកទ្រឹស្តី) បង្ហាញពីនិយមន័យ ប្រវត្តិទូទៅដែលពាក់ព័ន្ធ និងទ្រឹស្តីរបស់អ្នកប្រាជ្ញដែលពាក់ព័ន្ធនឹងការសិក្សាស្រាវជ្រាវ។

**ជំពូកទី៣៖** (លទ្ធផលនៃការស្រាវជ្រាវ) បង្ហាញពីស្ថានភាពទូទៅនៃផលប៉ះពាល់ដុល្លាររូបនីយកម្មមកលើសេដ្ឋកិច្ចកម្ពុជា គោលនយោបាយ ទស្សនវិស័យ និងបេសកកម្ម គោលដៅ របស់ធនាគារជាតិនៃកម្ពុជា។

**ជំពូកទី៤៖** (ការវិភាគពីចំណុចខ្លាំង និងចំណុចខ្សោយ) វិភាគនិងធ្វើការស្វែងយល់ពីចំណុចខ្លាំង និងចំណុចខ្សោយរបស់ប្រធានបទដែលពាក់ព័ន្ធ។

**ជំពូកទី៥៖** (សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍) សន្និដ្ឋានទៅលើចំណុចទាំងអស់ដែលមាននៅក្នុងអត្ថបទ និងផ្តល់អនុសាសន៍ទៅលើចំណុចដែលមានកង្វះខាតដើម្បីធ្វើការកែលម្អ។

# ជំពូកទី២
# រំលឹកទ្រឹស្តី

# ជំពូកទី២

# ផលប៉ះពាល់ដុល្លាររូបនីយកម្មមកលើសេដ្ឋកិច្ច

## ២.១ លក្ខណៈទូទៅនៃដុល្លាររូបបនីយកម្មមកលើសេដ្ឋកិច្ចកម្ពុជា

### ២.១.១ និយមន័យដុល្លាររូបនីយកម្ម

**ដុល្លាររូបនីយកម្ម(Dollarization)**គឺសំដៅដល់បាតុភូតដែលប្រជាពលរដ្ឋនៃប្រទេសមួយបានសម្រេចចិត្តជ្រើសរើសប្រើប្រាស់រូបិយប័ណ្ណបរទេស ទូយ៉ាងដូចជាប្រាក់ដុល្លារអាមេរិក ឬរូបិយប័ណ្ណផ្សេងទៀតជំនួស ឬទន្ទឹមនឹងការប្រើប្រាស់រូបិយវត្ថុជាតិនៃប្រទេសនោះ។ គួរបញ្ជាក់ថា ដុល្លាររូបនីយកម្ម មិនមែនសំដៅតែការប្រើប្រាក់ដុល្លារជំនួស រូបិយវត្ថុក្នុងស្រុកប៉ុណ្ណោះនោះទេ តែការប្រើប្រាក់ផ្សេងទៀត ដូចជាប្រាក់បាត ប្រាក់ដុង ឬប្រាក់យ៉ែន ក៏គេចាត់ទុកថាជាដុល្លាររូបនីយកម្មដែរ[1]។

**ដុល្លាររូបនីយកម្ម (Dollarization)** គឺជាការចាប់យករូបិយប័ណ្ណរបស់បរទេសណាមួយ សម្រាប់ធ្វើការទូទាត់ស្របច្បាប់នៅក្នុងប្រតិបត្តិការរូបិយវត្ថុ[2]។

**ដុល្លាររូបនីយកម្ម (Dollarization)** គឺជាការចាប់យករូបិយប័ណ្ណរបស់បរទេសណាមួយ សម្រាប់ធ្វើការទូទាត់ស្របច្បាប់នៅក្នុងប្រតិបត្តិការរូបិយវត្ថុ។

**ដុល្លាររូបនីយកម្ម (Dollarization)**មិនមែនសំដៅតែទៅលើការប្រើប្រាក់ដុល្លារជំនួសរូបិយវត្ថុក្នុងស្រុកប៉ុណ្ណោះនោះទេ តែជាកម្រិតនៃប្រតិបត្តិការនៅក្នុងវិស័យសេដ្ឋកិច្ចពិត និងវិស័យហិរញ្ញវត្ថុ ដែលប្រើប្រាស់នូវប្រាក់ដុល្លារអាមេរិក ដោយប្រៀបធៀបជាមួយនឹងប្រតិបត្តិការ ដែលប្រើប្រាស់រូបិយប័ណ្ណក្នុងស្រុក។ តាមនិយមន័យនៃដុល្លាររូបនីយកម្មនេះ ទទួលស្គាល់នូវការប្រើប្រាស់ប្រាក់ដុល្លារអាមេរិក ជាមធ្យោបាយនៃការលក់ដូរក្នុងសេដ្ឋកិច្ចមួយក្រៅពីសហរដ្ឋអាមេរិក[3]។

### ២.១.២ ប្រវត្តិដុល្លាររូបនីយកម្ម

មួយឆ្នាំបន្ទាប់ពីកម្ពុជាទទួលបានឯករាជ្យពីអាណានិគមបារាំង ធនាគារជាតិនៃកម្ពុជា (NBC) ត្រូវបានបង្កើតឡើងវិញនៅថ្ងៃទី ២៣ ខែធ្នូ ឆ្នាំ១៩៥៤ ដើម្បីទទួលបានស្វ័យភាពក្នុងការបោះពុម្ពប្រាក់រៀលជារូបិយវត្ថុជាតិ និងគ្រប់គ្រងប្រព័ន្ធធនាគារក្នុងប្រទេស។ ទោះយ៉ាងណា NBC ត្រូវបានបិទដោយសារតែរបបខ្មែរក្រហម (១៩៧៥ – ១៩៧៩) ដែលបានបំផ្លាញអគាររបស់ធនាគារកណ្តាល និងប្រព័ន្ធធនាគាររបស់ប្រទេសកម្ពុជា ដែលជាលទ្ធផលនៃការបញ្ចប់ការប្រើប្រាស់ប្រាក់រៀល។ កម្ពុជាជាប្រទេសដែលមានកម្រិតដុល្លាររូបនីយកម្មខ្ពស់ដោយសារព្រឹត្តិការណ៍ប្រវត្តិសាស្ត្រដែល UNTAC បានចំណាយថវិកាប្រមាណ ១៧ ពាន់លានដុល្លារអាមេរិកក្នុងការរៀបចំការបោះឆ្នោតថ្នាក់ជាតិលើកដំបូងរបស់កម្ពុជា។ ជាមួយនឹងបរិមាណសាច់ប្រាក់ដ៏ច្រើននេះនៅក្នុងសេដ្ឋកិច្ចតូចមួយ ធនាគារជាតិនៃកម្ពុជានៅពេលនោះមិនអាចគ្រប់គ្រងការបោះពុម្ពរូបិយវត្ថុ ដើម្បីជំនួសការចរាចរដុល្លារអាមេរិកបានទេ។ ហេតុដូច្នេះហើយ ប្រជាជនបានទទួលយកការប្រើប្រាស់ដុល្លារអាមេរិកនៅលើទីផ្សារតាំងពីពេលនោះមក។

---

[1] Cambonomic. Times. (30-ឧសភា-2020). *តើអ្វីជាដុល្លាររូបនីយកម្ម?* Retrieved September, 9 2025 from https://www.facebook.com/CambonomicTimes/posts/តើអ្វីជាដុល្លាររូបនីយកម្មដុល្លាររូបនីយកម្ម-គឺសំដៅដល់បាតុភូតដែលប្រជាពលរដ្ឋនៃប្រទេសម/138464247814397/

[2] សេដ្ឋកិច្ច. (28-វិច្ឆិកា-2019). *តើដុល្លាររូបនីយកម្មគឺជាអ្វី?* Retrieved September, 9 2025 from https://www.khsearch.com/qna/27047

[3] កម្ពុជាថ្មី. (19-មិថុនា-2023). *តើអ្វីជាដុល្លាររូបនីយកម្ម?* Retrieved September, 9 2025 from https://www.kampucheathmey.com/business-economic/529638

ដោយសារតែកម្រិតដុល្លារអាមេរិករូបនីយកម្មខ្ពស់ ប្រាក់បញ្ញើជារូបិយប័ណ្ណបរទេសមួយចំនួនធំមាននៅក្នុងប្រព័ន្ធធនាគារកម្ពុជា ដែលឆ្លុះបញ្ចាំងតាមរយៈសមាមាត្រនៃប្រាក់បញ្ញើជារូបិយប័ណ្ណបរទេសធៀបនឹងប្រាក់បញ្ញើសរុប ឬសមាមាត្រនៃប្រាក់បញ្ញើជារូបិយប័ណ្ណបរទេសធៀបនឹងរូបិយវត្ថុទូទៅ-សាច់ប្រាក់សរុបដែលចរាចរក្នុងសេដ្ឋកិច្ចរបស់ប្រទេស។ យោងតាមរបាយការណ៍ប្រចាំឆ្នាំ ២០២២ របស់ធនាគារជាតិនៃកម្ពុជា សមាមាត្រនៃប្រាក់បញ្ញើជារូបិយប័ណ្ណបរទេសធៀបនឹងរូបិយវត្ថុទូទៅមានចំនួន ៨៤,១ ភាគរយកាលពីឆ្នាំមុន ដែលបានកើនឡើង ១,១ ភាគរយធៀបនឹង ៨៣ ភាគរយក្នុងឆ្នាំ ២០២១ ខណៈដែលប្រាក់រៀលនៅក្នុងចរាចរមានកម្រិត ៧,៧ ភាគរយធៀបនឹងរូបិយវត្ថុទូទៅ ប្រាក់បញ្ញើនិងប្រាក់កម្ចីជារៀលមាន ៨,៩ ភាគរយនៃប្រាក់បញ្ញើសរុប និង ១១,២ ភាគរយនៃប្រាក់កម្ចីសរុបនៅកម្ពុជា។

លោកស្រី ជា សិរី ទេសាភិបាលរងធនាគារជាតិនៃកម្ពុជា មានប្រសាសន៍ថា រូបិយវត្ថុជាតិរបស់ប្រទេសនេះ ត្រូវបានបោះពុម្ពនៅឆ្នាំ ១៩៥៥ ប្រហែលមួយឆ្នាំបន្ទាប់ពីធនាគារកណ្ដាលត្រូវបានបង្កើតឡើង ហើយត្រូវបានប្រើប្រាស់ភាគច្រើនរហូតដល់ឆ្នាំ ១៩៧៥ ។ ទំនុកចិត្តលើប្រាក់រៀល ប្រព័ន្ធធនាគារកណ្ដាល និងរដ្ឋាភិបាលត្រូវបានបាត់បង់ទាំងស្រុងដោយសារសង្គ្រាម។ សិរី បានបន្តថា "លំហូរចូលនៃប្រាក់ដុល្លារអាមេរិកយ៉ាងច្រើនចូលទៅក្នុងសេដ្ឋកិច្ចបានបង្កើតទម្លាប់សម្រាប់ប្រជាជន និងវិស័យឯកជនរបស់យើងក្នុងការប្រើប្រាស់ដុល្លារអាមេរិកមកទល់ពេលនេះ។ "ប្រាក់ដុល្លារអាមេរិកបានចាប់ផ្តើមហូរចូលសេដ្ឋកិច្ចកម្ពុជានៅដើមទសវត្សរ៍ឆ្នាំ ១៩៩០ ហើយរដ្ឋាភិបាល និងធនាគារជាតិនៃកម្ពុជាបានចេញផ្សាយគោលនយោបាយលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល ជាពិសេសនៅដើមទសវត្សរ៍ឆ្នាំ ២០០០ ដោយសារស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច។ តាមទស្សនៈវប្បធម៌ ការលើកកម្ពស់ប្រាកក់រៀលដើម្បីបង្កើនមោទនភាពជាតិតាមរយៈគោលនយោបាយបដិដុល្លារូបនីយកម្ម ក៏ជាសញ្ញាណមួយពីការងើបឡើងវិញពីជម្លោះនៅក្នុងសង្គមកម្ពុជាផងដែរ។ ជាប្រវត្តិសាស្ត្រដុល្លារូបនីយកម្មនៅកម្ពុជាបានកើតឡើងដោយសារការខ្វះទំនុកចិត្តលើរូបិយវត្ថុជាតិ និងអស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចក្នុងអំឡុងពេលដែលប្រទេសកំពុងមានជម្លោះ ដែលបានអូសបន្លាយយ៉ាងយូរតាំងពីទសវត្សរ៍ឆ្នាំ១៩៧០មកម្លេះ[4]។

## ២.២ កត្តាដែលនាំឱ្យមានដុល្លារូបនីយកម្មមកលើសេដ្ឋកិច្ចកម្ពុជា

### ២.២.១ និយមន័យសេដ្ឋកិច្ច

**សេដ្ឋកិច្ច** (Economic) គឺជាការសិក្សាអំពីការកង្វះខាត និងផលប៉ះពាល់របស់វាចំពោះការប្រើប្រាស់ធនធាន ការផលិតទំនិញ និងសេវាកម្ម កំណើនផលិតកម្ម និងសុខុមាលភាពតាមពេលវេលា ព្រមទាំងបញ្ហាស្មុគស្មាញផ្សេងៗទៀតដែលមានសារៈសំខាន់ចំពោះសង្គម[5]។

**សេដ្ឋកិច្ច** (Economic) គឺជាការសិក្សាអំពីមនុស្សជាតិនៅក្នុងការងារជំនួញធម្មតានៃជីវិតរស់នៅ។ តាមទ្រឹស្តីសេដ្ឋវិទូបានអោយនិយមន័យសេដ្ឋកិច្ចខុសៗគ្នាជាច្រើនប៉ុន្តែន័យសុក្រឹតមួយគឺសេដ្ឋកិច្ចសិក្សាអំពីការប្រើប្រាស់បណ្តាធនធានដ៏កម្រដើម្បីបំពេញសេចក្តីត្រូវការរបស់មនុស្សដែលគ្មានព្រំដែន។ មានទ្រឹស្តីមួយទៀតបាននិយាយថា សេដ្ឋកិច្ចជាការសិក្សាអំពីយុទ្ធសាស្ត្ររបៀបប្រើប្រាស់ធនធានដើម្បីបំពេញបំណងគ្មានព្រំដែនរបស់មនុស្សដែលមានប្រព័ន្ធទាក់ទិននឹងប្រព័ន្ធើផលិតកម្ម ( ផ្នែកសេដ្ឋកិច្ចលនិងឧស្សាហកម្ម ) ប្រព័ន្ធ

[4] Khmer Time. (2024, March 25). *"ដុល្លារូបនីយកម្មឬបដិដុល្លារូបនីយកម្ម"*. Retrieved September, 10 2025 from https://www.khmertimeskh.com/501258485
5 University at Buffalo. (2024). *"Economic"*. Retrieved September, 10 2025 from https://arts-sciences.buffalo.edu/economics/about/ what-is-economics.html

បែងចែក (ផ្នែកពាណិជ្ជកម្ម ) និងប្រព័ន្ធប្រើប្រាស់ទំនិញសេដ្ឋកិច្ច ( ផ្នែកអតិថិជន ផ្នែកគមនាគមន៍និងដឹកជញ្ជូន ) [6]។

**សេដ្ឋកិច្ច(Economic)** ជាការសិក្សាអំពីមនុស្សជាតិនៅក្នុងអាជីវកម្មធម្មតានៃជីវិតប្រចាំថ្ងៃ។វាពិចារណាលើសកម្មភាពផ្ទាល់ខ្លួននិងសង្គមដែលមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយការជណ្តើមនិងការប្រើប្រាស់ឧបករណ៍សម្ភារៈដែលចាំបាច់សម្រាប់ការរស់នៅ[7]។

**សេដ្ឋកិច្ច (Economy)** គឺជាការសិក្សាអំពីវិធីដែលមនុស្សនិងសង្គម ប្រើប្រាស់ធនធានកម្រដើម្បីផលិត បែងចែក និងប្រើប្រាស់ទំនិញនិងសេវាកម្ម ដើម្បីបំពេញតម្រូវការនានា[8]។

### ២.២.២ ប្រវត្តិសេដ្ឋកិច្ច

**ប្រវត្តិសង្ខេបសេដ្ឋកិច្ច** គឺជាការសិក្សាអំពីប្រវត្តិដោយប្រើឧបករណ៍វិធីសាស្ត្រពីវិស័យសេដ្ឋកិច្ច ឬដោយផ្តោតលើបំណងជាក់លាក់ទៅលើបំណងសេដ្ឋកិច្ច។ការស្រាវជ្រាវត្រូវបានអនុវត្តដោយប្រើការរួមបញ្ចូលនៃវិធីសាស្ត្រប្រវត្តិសាស្ត្រ វិធីសាស្ត្រស្ថិតិសាស្ត្រ និងការដាក់ពាក្យគំនិតសេដ្ឋកិច្ចចំពោះស្ថានការណ៍ និងស្ថាប័នប្រវត្តិសាស្ត្រ

វិស័យនេះអាចរួមបញ្ចូលប្រធានបទជាច្រើន ដូចជា សមភាពហិរញ្ញវត្ថុ បច្ចេកវិទ្យា កម្លាំងពលកម្ម និងអាជីវកម្ម។ វាប្រកាន់យកការវិភាគសេដ្ឋកិច្ចក្នុងទិដ្ឋភាពប្រវត្តិសាស្ត្រដោយឆ្លុះបញ្ចាំងលើវា ដើម្បីយល់ដឹងអំពីរចនាសម្ព័ន្ធ និងការគិតអំពីសេដ្ឋកិច្ច។ដោយប្រើទាំងទិន្នន័យបរិមាណ (quantitative data) និងប្រភពគុណភាព (qualitative sources) អ្នកសិក្សាប្រវត្តិសាស្ត្រសេដ្ឋកិច្ចផ្តោតលើការយល់ដឹងអំពីបរិបទប្រវត្តិសាស្ត្រដែលឆ្លុះបញ្ចាំងលើព្រឹត្តិការណ៍សេដ្ឋកិច្ចសំខាន់ៗ។ ពួកគេមើលទៅលើកត្តាស្ថាប័ន (institutional dynamics) ក្នុងប្រព័ន្ធផលិតកម្ម កម្លាំងពលកម្ម និងមូលធន ព្រមទាំងផលប៉ះពាល់សេដ្ឋកិច្ចលើសង្គម វប្បធម៌ និងភាសា។ អ្នកវិភាគក្នុងវិស័យនេះអាចប្រើទស្សនៈផ្សេងៗគ្នាដូចជា សេដ្ឋកិច្ចសាមញ្ញ (Mainstream economics), សេដ្ឋកិច្ចអូទ្រីស (Austrian economics), សេដ្ឋកិច្ចម៉ាក្ស (Marxian Economics), សេដ្ឋកិច្ចសាលាឈីកាហ្គោ (Chicago school of economics), និងសេដ្ឋកិច្ចខេនស្យាន (Keynesian Economiccs)។ប្រវត្តិសាស្ត្រសេដ្ឋកិច្ចមានអនុវិស័យ (sub-disciplines) ច្រើន។ វិធីសាស្ត្រប្រវត្តិសាស្ត្រត្រូវបានអនុវត្តនៅក្នុងប្រវត្តិហិរញ្ញវត្ថុ និងអាជីវកម្ម ដែលមានការរំលែកជាមួយប្រវត្តិសង្គមដូចជា ប្រវត្តិសង្គមប្រជាជន និងប្រវត្តិពលកម្ម[9]។

### ២.២.៣ ទ្រឹស្តីសេដ្ឋកិច្ច

**ទ្រឹស្តីសេដ្ឋកិច្ច** ពាក់ព័ន្ធនឹងការសាងសង់គំរូដែលបានរចនាឡើងដើម្បីបំភ្លឺទិដ្ឋភាពផ្សេងៗនៃឥរិយាបទសេដ្ឋកិច្ច។ សំណុំនៃការសន្មត់ជាក់លាក់ណាមួយដែលបង្កើតក្នុងការសាងសង់គំរូមួយ អាស្រ័យទៅលើអ្វីដែលគេកំពុងព្យាយាមធ្វើគំរូ។ ការសន្មត់ទាក់ទងនឹងបញ្ហាមួយប្រហែលជាមិនពាក់ព័ន្ធខ្លាំងទេ ប្រសិនបើការផ្តោតអារម្មណ៍របស់បុគ្គលម្នាក់មានភាពខុសគ្នាខ្លះ។ ការពិតសេដ្ឋកិច្ចគឺស្មុគស្មាញខ្លាំងណាស់ ហើយមិន

[6] KHsearch. សេដ្ឋកិច្ច (2019, January 19). *តើសេដ្ឋកិច្ចគឺជាអ្វី?*. Retrieved September, 10 2025 from https://www.khsearch.com/qna/2013654

[7] Econlib. (2018, February 05). *និយមន័យសេដ្ឋកិច្ច*. Retrieved September, 10 2025 from https://www.econlib.org/library/Topics/College/whatiseconomics.html

[8] Robbins, L. C. (1932). *An Essay on the Nature and Significance of Economic*

[9] London School of Economics. (1971). *"ប្រវត្តិសេដ្ឋកិច្ច"*. Retrieved September, 10 2025 from https://en.m.wikipedia.org/wiki/ Economic_history

អាចយកគំរូតាមភាពស្មុគស្មាញទាំងអស់របស់វា។ ម៉ូដែល ដូចជាផែនទីគឺត្រូវជ្រើសរើសដោយជៀសមិនរួច។ ប៉ុន្តែដូចដែលយើងអាចបែងចែកវាងផែនទីល្អ និងអាក្រក់ គំរូខ្លះល្អជាងផែនទីផ្សេងទៀត។ សំណួរសំខាន់ក្នុងការវាយតម្លៃគំរូសេដ្ឋកិច្ចគឺថាតើពួកគេចាប់យកលក្ខណៈសំខាន់ៗនៃបញ្ហាដែលយើងចាប់អារម្មណ៍បានកម្រិតណា។ វាប្រហែលជាមិនងាយស្រួលទេក្នុងការឆ្លើយសំណួរនេះ។ ភាពមិនចុះសម្រុងគ្នាជាច្រើនរវាងអ្នកសេដ្ឋកិច្ចអាចបណ្តាលមកពីការពិតដែលថាពួកគេប្រើ (ប្រហែលជាដោយប្រយោល)គំរូសេដ្ឋកិច្ចផ្សេងៗគ្នា ដោយមិនបានដឹងច្បាស់ពីវា។ វាអាចត្រូវបានបន្ថែមថាការយល់ឃើញទូទៅដែលអ្នកសេដ្ឋកិច្ចតែងតែមិនយល់ស្របគ្នាទៅវិញទៅមកគួរឱ្យកត់សម្គាល់ថាមានចំនួននៃការមិនយល់ស្របក្នុងចំណោមអ្នកសេដ្ឋកិច្ច។

គំរូសេដ្ឋកិច្ចជាធម្មតាពាក់ព័ន្ធនឹងភ្នាក់ងារដូចជាអ្នកប្រើប្រាស់ ក្រុមហ៊ុន និងរដ្ឋាភិបាល ដែលអាកប្បកិរិយារបស់ពួកគេកំណត់លទ្ធផលសរុប។ ដើម្បីយល់ពីអ្វីដែលកើតឡើងនៅក្នុងសេដ្ឋកិច្ច វាចាំបាច់ក្នុងការពន្យល់ពីអាកប្បកិរិយារបស់ភ្នាក់ងារទាំងនេះ។ ជាធម្មតា នេះត្រូវបានធ្វើដោយការសន្មត់ថាពួកគេសមហេតុផល ដែលមានន័យថាពួកគេបង្កើនមុខងារគោលបំណងមួយចំនួន ទៅតាមកម្រិតដែលពាក់ព័ន្ធ។ ក្នុងករណីអ្នកប្រើប្រាស់ មុខងារគោលបំណងជាធម្មតាគឺជាមុខងារឧបករណ៍ប្រើប្រាស់ ដែលបង្ហាញពីចំណូលចិត្តរបស់ភ្នាក់ងារលើលទ្ធផលមួយចំនួន។ ឧទាហរណ៍មួយគឺនៅពេលដែលអតិថិជនដែលមានចំនួនទឹកប្រាក់ដែលបានផ្តល់ឱ្យត្រូវជ្រើសរើសចំនួនប៉ុន្មានដើម្បីប្រើប្រាស់ទំនិញផ្សេងៗគ្នា ។ មុខងារឧបករណ៍ប្រើប្រាស់តំណាងឱ្យចំណូលចិត្តរបស់គាត់តាមរបៀបដែលគាត់ភ្ជាប់ឧបករណ៍ប្រើប្រាស់កម្រិតខ្ពស់ទៅនឹងកញ្ចប់ទំនិញមួយលើទំនិញផ្សេងទៀត ប្រសិនបើគាត់ចូលចិត្តរបស់ពីមុន។ មានបច្ចេកទេសស្តង់ដារ ដែលធ្លាប់ស្គាល់ពីជំនាន់និស្សិតសេដ្ឋកិច្ច សម្រាប់អនុវត្តបែបនោះ[10]។

# ២.៣ ផលប៉ះពាល់នៃការកើនឡើងដុល្លារូបនីយកម្មមកលើសេដ្ឋកិច្ចកម្ពុជា

## ២.៣.១ និយមន័យដុល្លារ

**ដុល្លារ** គឺជាឯកតារូបិយប័ណ្ណរបស់សហរដ្ឋអាមេរិក ហើយដូច្នេះគឺជារូបិយប័ណ្ណបម្រុងមួយក្នុងពិភពលោក។ ដូចនេះ វាមិនមែនជារឿងគួរឱ្យភ្ញាក់ផ្អើលទេដែលពាក្យ Dollar ត្រូវបានគេប្រើជាលើកដំបូង និងសំខាន់បំផុតដើម្បីមានន័យថា ដុល្លារអាមេរិក។

**ដុល្លារ** គឺជាឯកតានៃប្រាក់ដែលត្រូវបានប្រើប្រាស់នៅក្នុងប្រទេសមួយចំនួនដូចជាសហរដ្ឋអាមេរិក អូស្ត្រាលី កាណាដា និងជាច្រើនទៀត។ រូបិយប័ណ្ណរបស់សហរដ្ឋអាមេរិកគឺដុល្លារសហរដ្ឋអាមេរិក (USD) ។ និមិត្តសញ្ញារបស់វាគឺ $ [11]។

**ដុល្លារ** គឺជារូបិយប័ណ្ណបម្រុងរបស់ធនាគារកណ្តាលដែលអាចប្តូរយកបានតាមតម្លៃសមមូលទៅនឹងលោហធាតុនៅធនាគារណាមួយរបស់ធនាគារកណ្តាលអាមេរិក[12]។

## ២.៣.២ ប្រវត្តិដុល្លារ

**ដុល្លារ**គឺជារូបិយប័ណ្ណផ្លូវការរបស់សហរដ្ឋអាមេរិកចាប់តាំងពីការអនុម័តច្បាប់រូបិយប័ណ្ណជាតិឆ្នាំ ១៧៨៥។ មុននោះសហរដ្ឋអាមេរិកបានប្រើរូបិយប័ណ្ណប្រទេសផ្សេងគឺ ផោនអង់គ្លេស និងរូបិយប័ណ្ណ

[10] WIKIPEDIA. “*ទ្រឹស្តីនៃសេដ្ឋកិច្ច*”. Retrieved October, 10 2025 from https://en.m.wikipedia.org/wiki/Economic_history

[11] SplashLearn. (dollar). “*និយមន័យដុល្លារ*”. Retrieved October, 10 2025 from https://www.splashlearn.com/math-vocabulary/money/

[12] AMS. (04-មិថុនា-2023). “*និយមន័យដុល្លារ*”. Retrieved October, 10 2025 from https://economy.ams.com.kh/

បរទេសផ្សេងៗ។ ដំបូងឡើយប្រាក់ដុល្លារត្រូវបានគេដាក់ឈ្មោះជាកាក់តែប៉ុណ្ណោះ ដោយក្រដាសប្រាក់ត្រូវបានដាក់ប្រើនៅឆ្នាំ១៨៦១ ហើយតម្លៃរបស់វាត្រូវបានគេគិតភ្ជាប់ជាមួយតម្លៃមាស ប្រាក់ និងទង់ដែង។ សភាអាមេរិកបានកែប្រែជាបន្តបន្ទាប់នូវការរចនាក្រដាសប្រាក់ និងតម្លៃដោយភ្ជាប់ជាមួយលោហធាតុ រហូតដល់ការត្រួតពិនិត្យរូបិយប័ណ្ណត្រូវបានអនុម័តជាផ្លូវការជាមួយច្បាប់សហព័ន្ធឆ្នាំ១៩១៣។ បន្ទាប់ពីការធ្វើកំណែទម្រង់នេះប្រាក់ដុល្លារគឺជារូបិយប័ណ្ណបម្រុងរបស់ធនាគារកណ្តាលដែលអាចប្តូរយកបានតាមតម្លៃសមមូលទៅនឹងលោហធាតុនៅធនាគារណាមួយរបស់ធនាគារកណ្តាលអាមេរិក។ នៅឆ្នាំ១៩៣៣ ប្រធានាធិបតី Franklin D. Roosevelt បានហាមឃាត់ការរក្សាទុកមាសជាកម្មសិទ្ធិឯកជនដោយប្រជាជនត្រូវប្តូរមាសទាំងអស់ទៅជាប្រាក់ដុល្លារ។ នៅឆ្នាំ១៩៤៤ គេបានបង្កើតកិច្ចព្រមព្រៀង Bretton Woods ដែលមាសគឺជាមូលដ្ឋានគ្រឹះនៃតម្លៃប្រាក់ដុល្លារអាមេរិក ហើយរូបិយប័ណ្ណផ្សេងទៀតត្រូវបានកំណត់ជាប្រាក់ដុល្លារដោយអត្រាថេរ។

រូបិយប័ណ្ណសំខាន់ៗទាំងអស់លើពិភពលោកផ្លាស់ប្តូរពីប្រព័ន្ធតម្លៃដែលមានមូលដ្ឋានលើលោហធាតុ ទៅជាអត្រាប្តូរប្រាក់ថេរ ដោយគេលក់មាសទៅឱ្យសហរដ្ឋអាមេរិកក្នុងតម្លៃ ៣៥ ដុល្លារក្នុងមួយអោន ហើយត្រូវបង់ជាដុល្លារអាមេរិក។ ស្តង់ដារមាសនេះដែលជាការភ្ជាប់តម្លៃរូបិយប័ណ្ណទៅនឹងតម្លៃមាស ត្រូវបានគេឈប់ប្រើប្រាស់ជាផ្លូវការនៅឆ្នាំ១៩៧១ នៅពេលដែលប្រធានាធិបតី Richard M. Nixon បានប្រកាសថាអាមេរិកនឹងមិនប្តូរមាសជារូបិយប័ណ្ណអាមេរិកទៀតទេ ហើយប្រព័ន្ធ Bretton Woods ត្រូវបានបញ្ចប់។ សព្វថ្ងៃនេះ USD គឺជារូបិយប័ណ្ណសេរីនៅលើទីផ្សារជួញដូររូបិយប័ណ្ណសកល។ ប្រាក់ដុល្លារអាមេរិកដើរតួជារូបិយប័ណ្ណបម្រុងរបស់ប្រទេសភាគច្រើន ដែលជំនួសឱ្យការស្តុកទុកមាស និងប្រាក់ ធនាគារកណ្តាលជុំវិញពិភពលោករក្សាទុនបំរុងជាប្រាក់ដុល្លារសម្រាប់ជាការការពារអតិផរណា។ យោងតាមធនាគារកណ្តាល គិតត្រឹមខែកក្កដាឆ្នាំ២០២១ មានរូបិយប័ណ្ណដុល្លារដែលកំពុងចរាចរមានជាង ២ ទ្រីលានដុល្លារ។ ចំនួននេះកើនឡើងដល់ជាង ២០,៤ ទ្រីលានដុល្លារប្រសិនបើគេគិតទាំងរង្វាស់ M2 នៃការផ្គត់ផ្គង់ប្រាក់ដែលរួមមានទ្រព្យមិនមែនសាច់ប្រាក់ដូចជាឧបករណ៍ទីផ្សារប្រាក់បញ្ញើ និងប្រាក់កម្ចីផ្សេងៗទៀត[13]។

**២.៣.៣ ប្រភេទដុល្លារ**

ដុល្លារគឺជាឈ្មោះនៃរូបិយប័ណ្ណច្រើនជាង 25 ។ ដុល្លារអាមេរិក (USD) – U.S. Dollar ដុល្លារកាណាដា (CAD) – Canadian Dollar ដុល្លារអូស្ត្រាលី (AUD) – Australian Dollar ដុល្លារសិង្ហបុរី (SGD) – Singapore Dollar ដុល្លារនូវែលសេឡង់ (NZD) – New Zealand Dollar ដុល្លារហុងកុង (HKD) – Hong Kong Dollar ។ប្រាក់ដុល្លារសហរដ្ឋអាមេរិក ដែលដាក់ឈ្មោះតាមរូបិយប័ណ្ណអន្តរជាតិដែលគេស្គាល់ថាជាដុល្លារអេស្ប៉ាញ ត្រូវបានបង្កើតឡើងក្នុងឆ្នាំ 1792 ហើយជាឈ្មោះដំបូងគេដែលនៅតែរស់រានមានជីវិត។ ផ្សេងទៀតរួមមាន ប្រាក់ដុល្លារអូស្ត្រាលី ប្រាក់ប្រ៊ុយណេ ប្រាក់ដុល្លារកាណាដា ប្រាក់ដុល្លារការាបៀនខាងកើត ប្រាក់ហុងកុង ប្រាក់ហ្សាម៉ាអ៊ីក ប្រាក់លីបេរីយ៉ា ប្រាក់ដុល្លារណាមីប៊ី ប្រាក់តៃវ៉ាន់ថ្មី ប្រាក់ដុល្លារនូវែលសេឡង់ ប្រាក់សិង្ហបុរី ទ្រីនីដាដ និងតូបាហ្គោ ដុល្លារ និងមួយចំនួនទៀត។ និមិត្តសញ្ញាសម្រាប់រូបិយប័ណ្ណទាំងនោះភាគច្រើនគឺជាសញ្ញាដុល្លារ $; និមិត្តសញ្ញាដូចគ្នានេះត្រូវបានប្រើប្រាស់ដោយ

---

13 Wikipedia. SplashLearn. *និយមន័យដុល្លារ*. Retrieved October, 1 2025 from https://en.m.wikipedia.org/wiki/

ប្រទេសជាច្រើនដោយប្រើរូបិយប័ណ្ណប៉េសូ។ ឈ្មោះ "ដុល្លារ" មានប្រភពមកពី " Thaler " ( មកពី Thal, អាឡឺម៉ង់សម្រាប់ជ្រលងភ្នំ ) នៅក្នុងឈ្មោះនៃកាក់ប្រាក់ 29 ក្រាមហៅថា Joachimsthaler minted in Bohemia ហ៊ុន ដែលសេដ្ឋវិទូ ហៅថា ការជំនួសទ្រព្យសកម្ម និងមួយទៀតដែលចាប់ផ្តើមបញ្ញើ និងសន្សំជារូបិយប័ណ្ណបរទេស ដែលត្រូវបានគេហៅថា ការជំនួសរូបិយវត្ថុ[14]។

[14] Wikipedia. SplashLearn. "*ប្រភេទនៃដុល្លារ*". Retrieved October, 1 2025. from https://en.m.wikipedia.org/wiki/

# ជំពូកទី៣
# លទ្ធផលនៃការស្រាវជ្រាវ

# ជំពូកទី៣
# ផលប៉ះពាល់ដុល្លារូបនីយកម្មលើសេដ្ឋកិច្ចកម្ពុជា

## ៣.១ ស្ថានភាពទូទៅនៃដុល្លារូបនីយកម្មលើសេដ្ឋកិច្ចកម្ពុជា

### ៣.១.១ ប្រវត្តិនៃដុល្លារូបនីយកម្ម

**ដុល្លារូបនីយកម្ម** ត្រូវបានកត់សម្គាល់ថាមានវត្តមាននៅប្រទេសកម្ពុជាក្នុងកំឡុងឆ្នាំ ១៩៩៣ តាមរយៈគម្រោងរបស់អង្គការសហប្រជាជាតិ ឈ្មោះ អ៊ុនតាក់ (UNTAC) ដែលមានទឹកប្រាក់សរុប ១,៧០០ លានដុល្លារ។ ហើយចាប់ពីពេលនោះមក លុយដុល្លារចាប់ផ្តើមមានចរាចរណ៍ទូលំទូលាយក្នុងសេដ្ឋកិច្ចប្រទេសកម្ពុជា។ ប៉ុន្តែជាក់ស្តែង គេឃើញមានចរាចរណ៍លុយដុល្លារមួយចំនួនតូចរួចមកហើយតាំងពីសម័យសាធារណរដ្ឋខ្មែរមកម្ល៉េះ (១៩៧០-១៩៧៥)។

### ៣.១.២ ចក្ខុវិស័យ ធនាគារជាតិ

**ក. ចក្ខុវិស័យ**

គោលបំណងរបស់ធនាគារជាតិគឺដើម្បីបង្កើនប្រតិបត្តិការរបស់ធនាគារ សម្រាប់ចូលរួមកសាងជាតិ និងជានាំឱ្យប្រជាជនកម្ពុជាទទួលបាននូវសេវាធនាគារពាណិជ្ជ ដែលមានអត្រាការប្រាក់ប្រកួតប្រជែង និងបង្កើនការសន្សំដើម្បីផ្តល់នូវមូលនិធិឱ្យមានកំណើនសេដ្ឋកិច្ចកាន់តែខ្លាំងនៃប្រទេសកម្ពុជា និងមានសក្តានុពលភាពខ្ពស់ផងដែរ។

**ខ. បេសកកម្ម**

បេសកកម្មចម្បងរបស់ធនាគារជាតិនៃកម្ពុជា ដែលជាធនាគារកណ្តាលរបស់ប្រទេសកម្ពុជា គឺការកំណត់ និងដឹកនាំគោលនយោបាយរូបិយវត្ថុ ក្នុងគោលដៅរក្សាស្ថិរភាពថ្លៃ សំដៅរួមចំណែកជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា។

**គ. គោលដៅ**

ធនាគារជាតិនៃកម្ពុជាមានគោលដៅគឺកំណត់ និងដឹកនាំគោលនយោបាយរូបិយវត្ថុ សំដៅរក្សាស្ថិរភាពថ្លៃ ដើម្បីរួមចំណែកជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ច ក្នុងក្របខ័ណ្ឌនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា។ តាមរយៈការអនុវត្តគោលនយោបាយរូបិយវត្ថុប្រកបដោយភាពប្រុងប្រយ័ត្ន អតិផរណាត្រូវបានគ្រប់គ្រងឱ្យស្ថិតក្នុងកម្រិតទាបក្នុងអត្រាមធ្យមប្រចាំឆ្នាំតិចជាង ៥% ដែលសមស្របសម្រាប់ប្រទេកំពុងអភិវឌ្ឍន៍។ ទោះជាយ៉ាងនេះក្តីក្នុងបរិការណ៍សេដ្ឋកិច្ចដែលមានកម្រិតដុល្លារូបនីយកម្មខ្ពស់ ប្រសិទ្ធភាពនៃការអនុវត្តគោល នយោបាយរូបិយវត្ថុនៅមានកម្រិតនៅឡើយស្របពេលដែលធនាគារជាតិនៃកម្ពុជាពុំមាន លទ្ធភាពគ្រប់គ្រាន់ក្នុងការដើរតួជាអ្នកឱ្យខ្ចីចុងក្រោយ ។ បច្ចុប្បន្ន ឧបករណ៍គោលនយោបាយ រូបិយវត្ថុដែលត្រូវបានប្រើប្រាស់ដើម្បីរក្សាស្ថិរភាពថ្លៃ គឺការដាក់អត្រាប្រាក់បម្រុងកាតព្វកិច្ច និង ការធ្វើអន្តរាគមន៍លើទីផ្សារប្តូរប្រាក់។ ជាមួយគ្នានេះ ធនាគារជាតិនៃកម្ពុជាកំពុងអភិវឌ្ឍន៍ ឧបករណ៍គោលនយោបាយរូបិយវត្ថុបន្ថែមដើម្បីពង្រឹងប្រសិទ្ធភាពគោលនយោបាយរូបិយវត្ថុ តាមរយៈការចេញផ្សាយមូលបត្រអាចជួញដូរបាន ការអភិវឌ្ឍន៍ទីផ្សារអន្តរធនាគារនិងទីផ្សារ រូបិយវត្ថុ និងការពង្រឹងការប្រើប្រាស់ប្រាក់រៀល។

## ៣.១.៣ រចនាសម្ព័ន្ធគ្រប់គ្រងតួនាទី និងភារកិច្ចរបស់ ធនាគារជាតិ



ក្រុមប្រឹក្សាភិបាលជាគណៈគ្រប់គ្រង ដែលមានសិទ្ធិក្នុងការធ្វើសេចក្តីសម្រេចលើផែនការ និងគោលនយោបាយរបស់ធនាគារជាតិនៃកម្ពុជា នៅធនាគារជាតិនៃកម្ពុជា ។ ក្រុមប្រឹក្សាភិបាលកំពូលមានសមាសភាពចំនួន ៧រូប ដែលមានទេសាភិបាលជាប្រធាន និងមានតួនាទីជានាយកប្រតិបត្តិនៃធនាគារជាតិនៃកម្ពុជា ជាអ្នករាយការណ៍ជូនក្រុមប្រឹក្សាភិបាល និងជាអ្នកទទួលខុសត្រូវអនុវត្តគោលនយោបាយ និងប្រតិបត្តិការប្រចាំថ្ងៃរបស់ធនាគារជាតិនៃកម្ពុជា ។ ទេសាភិបាលត្រូវបានតែងតាំង ដាក់ជំនួស និងបញ្ឈប់ពីតំណែងដោយព្រះ រាជក្រឹត្យ ដែលយោងតាមសំណើរបស់រាជរដ្ឋាភិបាល ។ ក្រុមប្រឹក្សាភិបាលត្រូវជួបប្រជុំគ្នាយ៉ាងតិច ២ ខែម្តង ។

ធនាគារជាតិនៃកម្ពុជាគឺជាអាជ្ញាធររូបិយវត្ថុ និងត្រួតពិនិត្យប្រព័ន្ធធនាគារនៅកម្ពុជា ។ ក្នុងនាមជាអាជ្ញាធររូបិយវត្ថុ ធនាគារជាតិនៃកម្ពុជាមានសិទ្ធិផ្តាច់មុខក្នុងការបោះផ្សាយប្រាក់រៀលដែលជារូបិយវត្ថុជាតិ ។ ធនាគារជាតិនៃកម្ពុជាជាអ្នករក្សាស្ថិរភាពរូបិយវត្ថុ ។ ក្នុងន័យនេះ ធនាគារជាតិនៃកម្ពុជាជាអ្នករៀបចំតាក់តែងអនុវត្ត និងត្រួតពិនិត្យគោលនយោបាយរូបិយវត្ថុនិងប្តូរប្រាក់ ដោយប្រឹក្សាយោបល់ជាមួយរាជរដ្ឋាភិបាលក្នុងក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា ។ លើសពីនេះទៀត ធនាគារជាតិនៃកម្ពុជាធ្វើការវិភាគស្ថានភាពសេដ្ឋកិច្ចនិងរូបិយវត្ថុជាប្រចាំ ចេញផ្សាយ របាយការណ៍និងព្រឹត្តបត្រផ្សេងៗ ត្រួតពិនិត្យប្រព័ន្ធទូទាត់ជាតិ តម្លើងតារាងស្ថិតិជញ្ជីងទូទាត់ និងចូល រួមក្នុងការគ្រប់គ្រង បំណុល និងឥណទេយ្យក្រៅប្រទេស ។

- កំណត់គោលដៅគោលនយោបាយរូបិយវត្ថុដោយពិគ្រោះជាមួយរាជរដ្ឋាភិបាលក្នុងក្របខ័ណ្ឌនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា
- ត្រិះរិះរកអនុវត្តត្រួតពិនិត្យគោលនយោបាយរូបិយវត្ថុ និងគ្រប់គ្រងការប្តូរប្រាក់ឱ្យសម្រេចទៅតាមគោលដៅដែលបានកំណត់
- ធ្វើការវិភាគស្ថានភាពសេដ្ឋកិច្ច និងរូបិយវត្ថុជាប្រក្រតីរួចចេញផ្សាយលទ្ធផលហើយលើកជាសំណើរ និងវិធានការជូនរាជរដ្ឋាភិបាល
- ផ្តល់ឬដកហូតអាជ្ញាប័ណ្ណអាជីវកម្មចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងគ្រឹះស្ថានដែលពាក់ព័ន្ធដូចជាស្នងការគណនីគ្រឹះស្ថានចុះបញ្ជីជាដើម ព្រមទាំងចេញបទបញ្ជារ និងត្រួតពិនិត្យគ្រឹះស្ថានទាំងនោះ
- ត្រួតពិនិត្យប្រព័ន្ធទូទាត់ក្នុងព្រះរាជាណាចក្រកម្ពុជា និងកែលម្អប្រសិទ្ធភាពនៃការទូទាត់អន្តរធនាគារ
- ទទួលភារកិច្ចផ្តាច់មុខជាអ្នកបោះផ្សាយរូបិយវត្ថុជាតិនៃព្រះរាជាណាចក្រកម្ពុជា
- ទទួលខុសត្រូវ និងអនុវត្តក្នុងនាមព្រះរាជាណាចក្រកម្ពុជានៃកិច្ចការទាំងឡាយដែលជាលទ្ធផលនៃការចូលរួមរបស់ព្រះរាជាណាចក្រកម្ពុជាជាមួយស្ថាប័ណ្ណអន្តរជាតិសាធារណក្នុងកិច្ចការធនាគារឥណទានបិយវត្ថុ
- តំឡើងតារាងជញ្ជាំងទូទាត់
- ចូលរួមក្នុងការគ្រប់គ្រងបំណុល និងឥណទេយ្យជាមួយប្រទេសក្រៅ
- ចូលរួមក្នុងការបង្កើតការត្រួតពិនិត្យទីផ្សាររូបិយវត្ថុ និងទីផ្សារហិរញ្ញវត្ថុ

- ផ្តល់ឬដកហូតអាជ្ញាប័ណ្ណចំពោះគ្រឹះស្ថានដែលចូលរួមក្នុងអាជីវកម្មទីផ្សារប្តូរប្រាក់ មូលបត្រត្បូងថ្ម និងលោហធាតុមានតម្លៃព្រមទាំងចេញបទបញ្ជា ត្រួតពិនិត្យគ្រឹះស្ថានទាំងនេះ
- កំណត់អត្រាការប្រាក់។

វិធានការទីផ្សាររួមដែលបានដាក់ចេញតាំងពីដើមទសវត្សរ៍ឆ្នាំ២០០០គួបផ្សំនឹងគោលនយោបាយដែលផ្តោតលើស្ថិរភាពតម្លៃនៃប្រាក់រៀលទទួលបាននូវលទ្ធផលល្អប្រសើរ។ វិធានការទាំងនោះរួមមានការកំណត់ និងការបើកប្រាក់បៀវត្សរ៍មន្ត្រីរាជការ ទឹកភ្លើង និងពន្ធជាប្រាក់រៀល។ រាជរដ្ឋាភិបាលបានចេញសេចក្តីប្រកាសឱ្យពាណិជ្ជករកំណត់តម្លៃទំនិញ និងសេវាកម្មជាប្រាក់រៀល ខណៈដែល NBC បានបង្កើតប្រព័ន្ធឌីជីថលសម្រាប់អ្នកប្រើប្រាស់ និងអ្នកជំនួញអាចទូទាត់ប្រាក់ជាប្រាក់រៀលបានយ៉ាងងាយស្រួល សុវត្ថិភាព និងប្រសិទ្ធភាព ជាពិសេសតាមរយៈប្រព័ន្ធបាគង និង KHQR។ លើសពីនេះការសម្រេចបានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ដែលជំរុញដោយសុខសន្តិភាពនិងស្ថិរភាពនយោបាយ បានពង្រឹងជំនឿទុកចិត្តរបស់សាធារណជនលើប្រាក់រៀល។ យោងតាមរបាយការណ៍ប្រចាំឆ្នាំរបស់ធនាគារជាតិនៃកម្ពុជាឆ្នាំ២០២៣ប្រតិបត្តិការតាមរយៈប្រព័ន្ធទូទាត់បាគងបានកើនឡើងគួរឱ្យកត់សម្គាល់ ដោយមានចំនួនប្រតិបត្តិការសរុបជាង ២០០ លានដងពោលគឺកើនឡើង៥ ដងបើធៀបនឹងឆ្នាំ២០២២។ គួរកត់សម្គាល់ថា ប្រតិបត្តិការទាំងនេះប្រហែល៣៤% ត្រូវបានធ្វើឡើងជាប្រាក់រៀល ហើយប្រតិបត្តិការជាប្រាក់រៀលមានទំហំ ៨១ ទ្រីលានរៀល និង ជាដុល្លារអាមេរិក ៥៣ ប៊ីលានដុល្លារអាមេរិក។

ទិន្នន័យនេះបង្ហាញពីការកើនឡើងនៃការប្រើប្រាស់ប្រាក់រៀលក្នុងប្រតិបត្តិការហិរញ្ញវត្ថុ ស្របតាមកិច្ចខិតខំប្រឹងប្រែងនៃការអនុវត្តបដិដុល្លារូបនីយកម្ម។ បច្ចុប្បន្នប្រព័ន្ធទូទាត់បាគងដែលជាប្រព័ន្ធទូទាត់ចម្បងនៅកម្ពុជា បានតភ្ជាប់គ្រឹះស្ថានហិរញ្ញវត្ថុចំនួន៧៤ ដែលក្នុងនោះ ៥៨គ្រឹះស្ថាន កំពុងចូលរួមយ៉ាងសកម្មក្នុងប្រតិបត្តិការទូទាត់។ ឧបករណ៍នយោបាយរូបិយវត្ថុដែលត្រូវបានប្រើដើម្បីសម្រេចបាននូវស្ថិរភាពថ្លៃ រួមមានការកំណត់អត្រាប្រាក់បម្រុងកាតព្វកិច្ចនិងការធ្វើអន្តរាគមន៍លើទីផ្សារប្តូរប្រាក់។ ទន្ទឹមនឹងនេះ NBC បានបង្កើតឧបករណ៍នយោបាយរូបិយវត្ថុបន្ថែមដើម្បីបង្កើនប្រសិទ្ធភាពនយោបាយរូបិយវត្ថុតាមរយៈការចេញមូលបត្រអាចជួញដូរបាន (NCDs) ការអភិវឌ្ឍអន្តរធនាគារនិងទីផ្សាររូបិយវត្ថុ ការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល ជាដើម។

## ៣.២ កត្តាដែលនាំឱ្យមានដុល្លារូបនីយកម្មមកលើសេដ្ឋកិច្ចកម្ពុជា

### ៣.២.១ ស្ថានភាពសន្តិសុខក្នុងប្រទេសនិងការបាត់បង់ទំនុកចិត្តពីសាធារណជនទៅលើរូបិយប័ណ្ណជាតិ "រៀល"



ប្រទេសកម្ពុជាបានឆ្លងកាត់សង្គ្រាមស៊ីវិល ដែលគ្រានោះប្រាក់រៀលគ្មានតម្លៃ និងគ្មានដំណើរការ រឺចរាចរណ៍ក្នុងប្រព័ន្ធសេដ្ឋកិច្ចឡើយ។ ក្នុងឆ្នាំ១៩៨០ នៅពេលដែលប្រាក់រៀលត្រូវបានអោយធ្វើចរាចរណ៍ឡើងវិញ ហើយទោះបីសង្គ្រាមរបបប៉ុលពតចប់ក្តី សាធារណជនហាក់បាត់បង់ទំនុកចិត្តទៅលើការប្រើប្រាស់ប្រាក់រៀលឡើងវិញ។ ដោយសារលំហូរចូលនៃប្រាក់ដុល្លារផង សាធារណជនភាគច្រើននិយមប្រើប្រាស់ប្រាក់ដុល្លារជាងប្រាក់រៀល។ ការបាត់បង់ទំនុកចិត្តលើលុយរៀល បានធ្វើឱ្យដុល្លារអាមេរិកក្លាយទៅជារូបិយប័ណ្ណដែលត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយបំផុត នៅក្នុងប្រទេសកម្ពុជា ពោលគឺ ត្រូវបានគេប្រើច្រើនជាងលុយរៀល ដែលជារូបិយប័ណ្ណជាតិទៅទៀត។ ហេតុនេះហើយបានជាធ្វើឱ្យប្រជាជនមិនមានទំនុកចិត្តលើលុយរៀល អ្នកមានលុយមិនចង់រក្សាទុកលុយរៀលច្រើន ហើយនាំគ្នាស្វះស្វែងរកកន្លែងទុកលុយជាដុល្លារ ឬលុយបរទេសផ្សេងទៀត ដែលគេគិតថាមានហានិភ័យតិចជាង។ តើការចាយលុយដុល្លារយ៉ាងទូលំទូលាយបែបនេះអាចបង្កនូវផលវិបាកអ្វីខ្លះ?

កម្ពុជា ដុល្លារអាមេរិក ត្រូវបានគេប្រើប្រាស់ជាមធ្យោបាយសម្រាប់កំណត់តម្លៃ សម្រាប់ទូទាត់ និងសម្រាប់សន្សំ ពោលគឺ តួនានៅទីសំខាន់ៗទាំង៣ នៃរូបិយប័ណ្ណ។ តម្លៃទំនិញភាគច្រើនត្រូវគិតជាដុល្លារ ការទិញដូរភាគច្រើនត្រូវទូទាត់ដោយប្រើលុយដុល្លារ ហើយការដាក់លុយសន្សំនៅធនាគារ ភាគច្រើនត្រូវដាក់ជាដុល្លារ។ យោងតាមមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) នៅកម្ពុជា ដុល្លារត្រូវបានប្រើប្រាស់រហូតទៅដល់ប្រមាណជា ៨០% នៃបរិមាណសាច់ប្រាក់សរុប ដែលចរាចរនៅលើទីផ្សារ ហើយខុសពីប្រទេសជិតខាង ដូច

ជា ប្រទេសឡាវ ជាដើម ដែលការប្រើលុយដុល្លារមានការថយចុះធៀបនឹងលុយជាតិ និន្នាការនៃការប្រើលុយដុល្លារនៅកម្ពុជាវិញមិនមានការថយចុះទាល់តែសោះ បើទោះបីជាកម្ពុជាមានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ហើយមានអត្រាអតិផរណាមិនខ្ពស់ហួសហេតុក៏ដោយ។

ទន្ទឹមនឹងនេះ ធនាគារជាតិនៃកម្ពុជា បានពិនិត្យតាមដានយ៉ាងលម្អិតអំពីដំណើរវិវត្តន៍នៃចរាចរប្រាក់ដុល្លារ ឬហៅថាដុល្លារូបនីយកម្ម ក្នុងសកម្មភាពសេដ្ឋកិច្ចនៅកម្រិតមូលដ្ឋានដែលសំដៅដល់អង្គភាព គ្រួសារ សហគ្រាស និងគ្រឹះស្ថានហិរញ្ញវត្ថុនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ដើម្បីត្រៀមដាក់ចេញនូវឧបករណ៍គោលនយោបាយលើកកម្ពស់ប្រាក់រៀលថ្មីៗបន្ថែមទៀត។ គម្រោងសិក្សាស្រាវជ្រាវដ៏ស៊ីជម្រៅនេះ ត្រូវបានអនុវត្តរួមគ្នាដោយធនាគារជាតិនៃកម្ពុជា និងវិទ្យាស្ថាន JICA Ogata Sadako Research Institute កាលពីឆ្នាំ២០១៤ និងឆ្នាំ ២០២៧ ក្នុងគោលបំណងប្រមូលមីក្រូទិន្នន័យនៅកម្រិតមូលដ្ឋានទូទាំងប្រទេស ដោយសារតែទិដ្ឋភាពក៏ដូចជាស្ថានភាពដុល្លារូបនីយកម្មនៅកម្ពុជាកន្លងមកត្រូវបានសិក្សាពិនិត្យតាមដាននៅត្រឹមតែកម្រិតម៉ាក្រូ ឬហៅថាវិស័យធនាគារ និងហិរញ្ញវត្ថុប៉ុណ្ណោះ។ សៀវភៅស្រាវជ្រាវរបស់ធនាគារជាតិនៃកម្ពុជាបានបញ្ជាក់ថា ក្នុងចំណោមក្រដាសប្រាក់រៀល ដុល្លារ បាត និងដុង ក្រដាសប្រាក់ដុល្លារបានគ្របដណ្តប់រហូតដល់ទៅជិត ៧៧ ភាគរយក្នុងខ្ទង់ចំណាយរបស់អង្គភាពគ្រួសារ លើម៉ូតូ និងរថយន្ត ខណៈប្រាក់រៀលបានត្រឹម ២០,៤ ភាគរយ តាមពីក្រោយដោយក្រដាសប្រាក់បាត ២,៦ ភាគរយ ប៉ុន្តែ ក្រដាសប្រាក់ដុងមិនមានចំណែកទេ។ អ្នកស្រាវជ្រាវក៏បានរកឃើញផងដែរថា អង្គភាពគ្រួសារប្រើប្រាស់ក្រដាសប្រាក់ដុល្លារច្រើនជាងក្រដាសប្រាក់រៀល ទៅលើខ្ទង់ចំណាយគ្រឿងសង្ហារឹម ផ្ទះជួល ប្រព័ន្ធទំនាក់ទំនង ដែលដូចជាកាតទូរស័ព្ទ និងអ៊ីនធើណេត ជាដើម ព្រមទាំងសំភារៈប្រើប្រាស់ចាំបាច់ផ្ទាល់ខ្លួន ដំណើរកម្សាន្ត សម្លៀកបំពាក់ និងស្បែកជើង ក្នុងចន្លោះពី ១២,២ ភាគរយទៅជិត ៤៦ ភាគរយ។ទោះជាយ៉ាងនេះក្តី ទិន្នន័យស្រាវជ្រាវរបស់ធនាគារជាតិនៃកម្ពុជា និងអង្គការ JICA នៅក្នុងសៀវភៅស្រាវជ្រាវដដែលបានបញ្ជាក់ថា អង្គភាពគ្រួសារទូទាំងប្រទេស កម្ពុជា រកប្រាក់ចំណូលជារូបិយវត្ថុជាតិប្រមាណ ៧១,៣ ភាគរយ នៃប្រាក់ចំណូលគ្រួសារសរុប ខណៈដែលប្រាក់ដុល្លារអាមេរិក ប្រាក់បាតថៃ និងដុងវៀតណាម ចូលរួមចំណែក ២៣,១ ភាគរយ ៥,៣ ភាគរយ និង ០,៣ ភាគរយ រៀងគ្នា។

### ៣.២.២ បញ្ហាសេដ្ឋកិច្ច និងការធ្លាក់ចុះនៃលុយរៀល

ក្នុងឆ្នាំ១៩៩៣ ចំណូលពន្ធនៅមានកម្រិតទាបដោយសារតែសេដ្ឋកិច្ចមិនដំណើរការល្អ ហើយគោលនយោបាយសារពើពន្ធក៏នៅមានកម្រិត ម្យ៉ាងកម្ពុជាក៏មិនទាន់មានជំនួយពីបរទេសនៅឡើយ។ ហេតុនេះ កំណើនសេដ្ឋកិច្ចកម្ពុជានៅមានសន្ទុះយឺត ដែលធ្វើអោយប្រាក់រៀលធ្លាក់តម្លៃនិងមានអតិផរណាខ្ពស់។ ក្រៅពីនេះ ការប្រើប្រាស់ប្រាក់ដុល្លារលើសកម្មភាពសេដ្ឋកិច្ចនិងពាណិជ្ជកម្មនៅតំបន់ទីក្រុងមានភាពសកម្មខ្លាំង ហើយ៩០% នៃប្រាក់កម្ចីពីធនាគារពាណិជ្ជកម្មជាលុយដុល្លារ។ ដុល្លារូបនីយកម្ម បានធ្វើឱ្យកម្ពុជាខាតបង់ប្រាក់ចំណូលពីការបោះពុម្ពក្រដាសប្រាក់រូបិយវត្ថុ ជាតិ (Seigniorage)។ ចំណូលពីការបោះពុម្ពក្រដាសប្រាក់គឺជាភាពខុសគ្នារវាងតម្លៃចារឹកនិងចំណាយ ផលិតកម្មក្នុងការបោះពុម្ព។ ក្នុងសេដ្ឋកិច្ចដុល្លារូបនីយកម្មខ្ពស់ កម្ពុជាបានបាត់បង់លទ្ធភាពក្នុងការ ទទួលបានចំណូលពីការបោះពុម្ពនេះ ដោយសារសាធារណជនកាន់រូបិយប័ណ្ណប្រាក់ដុល្លារអាមេរិក ជាចម្បងជំនួសឱ្យរូបិយវត្ថុជាតិ។ ការកាន់កាប់នេះមានន័យស្មើនឹងការខាតបង់ចំណូលពីការបោះពុម្ព រូបិយវត្ថុជាតិ ហើយបែរជាផ្តល់ចំណូលទៅឱ្យធនាគារកណ្តា

លអាមេរិកដែលជាអ្នកបោះផ្សាយប្រាក់ ដុល្លារអាមេរិកទៅវិញ។ នៅពេលដែលរូបិយវត្ថុជាតិត្រូវបានប្រើប្រាស់កាន់តែច្រើន រាជរដ្ឋាភិបាលក៏អាចទទួលបាន នូវប្រាក់ចំណូល Seigniorage កាន់តែច្រើនផងដែរ ដែលនឹងអនុញ្ញាតឱ្យរាជរដ្ឋាភិបាលអាចគរពូនទ្រព្យ សម្បត្តិជាតិ ឬយកទៅប្រើប្រាស់សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិសំខាន់ៗ ដូចជាហេដ្ឋារចនាសម្ព័ន្ធ ការជួយកាត់បន្ថយភាពក្រីក្រដោយឧបត្ថម្ភប្រាក់ជូនប្រជាជននៅតាមទីជនបទ ជាដើម។ យោងតាម ទិន្នន័យរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ កម្ពុជាបានទទួលបានចំណូលពីការបោះពុម្ពក្រដាសប្រាក់ ជាមធ្យមក្នុងចន្លោះពី ០,៤% ទៅ ២,៤% នៃផ.ស.ស ក្នុង ១ឆ្នាំ នៅអំឡុងឆ្នាំ១៩៩៤-២០០១ ហើយ បានកើនឡើងដល់ប្រមាណ ៥% នៃ ផ.ស.ស នៅឆ្នាំ២០១០ ដែលជាកម្រិតទាបបំផុតបើធៀបនឹង ប្រទេសដែលសេដ្ឋកិច្ចមិនស្ថិតក្នុងស្ថានភាពដុល្លារូបនីយកម្ម។ គួរបញ្ជាក់ថាចំណូលពីការបោះពុម្ពក្រដាសប្រាក់ត្រូវបានគណនាដោយប្រើប្រាស់វិធីសាស្ត្រ ពីរយ៉ាងគឺ វិធីសាស្ត្រប្រាក់បម្រុង (Reserve Money Method) គណនាដោយយកបម្រែបម្រួលប្រាក់ បម្រុងរូបិយវត្ថុ (Change in Reserve Money) ធៀបនឹងផ.ស.ស និងវិធីសាស្ត្រចំណូលរបស់ធនាគារ កណ្តាល (Central Bank Profit Method) គណនាដោយយកផលសងរវាងចំណូលការប្រាក់ពីទ្រព្យ សកម្មរបស់ធនាគារកណ្តាល (Central Bank's Interest Income) និងការប្រាក់ដែលផ្តល់ទៅឱ្យ ជាប្រាក់រៀលរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅធនាគារកណ្តាល ធៀបនឹងផ.ស.ស។ សម្រាប់វិធីសាស្ត្រទី២ ដោយសារធនាគារជាតិនៃកម្ពុជាពុំបានផ្តល់ជាការប្រាក់ដល់ប្រាក់បញ្ញើជា ប្រាក់រៀលរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ចំណូលពីការបោះពុម្ពក្រដាសប្រាក់ត្រូវស្មើនឹង ចំណូលការប្រាក់ពីទ្រព្យសកម្មរបស់ធនាគារជាតិនៃកម្ពុជាធៀបនឹងផ.ស.សតែម្តង។ប្រសិនបើនៅកម្ពុជា ដុល្លារមិនត្រូវបានអនុញ្ញាតឱ្យធ្វើចរាចរយ៉ាងទូលំទូលាយដូចសព្វថ្ងៃនេះទេ ដើម្បីអាចទុកលុយជាដុល្លារ គេប្រាកដជាត្រូវយកលុយទៅទុកនៅក្នុងធនាគារឯក្រៅប្រទេស ហើយមូលធនដែលជាកត្តាសំខាន់សំរាប់កំណើនសេដ្ឋកិច្ចជាតិ នឹងត្រូវហូរចេញទៅក្រៅប្រទេស។ ឬក្នុងករណីខ្លះទៀតអ្នកមានលុយដែលមិនចង់ទុកជាលុយរៀលហើយក៏មិនអាចទុកជាដុល្លារនៅក្នុងប្រទេសបាន អាចនាំគ្នាយកលុយទៅទិញមាសទុកជំនួសវិញ។ ការទុកលុយជាមាសនេះ ក៏មិនខុសពីការយកលុយទៅទុកនៅឯធនាគារបរទេសដែរ គឺវានាំឱ្យកម្ពុជាត្រូវបាត់បង់មូលធន សម្រាប់ជំរុញកំណើនសេដ្ឋកិច្ច។

បច្ចុប្បន្នប្រាក់រៀលមានប្រហែល១០%នៃប្រាក់ដុល្លារដែលកំពុងចរាចរនៅលើទីផ្សារ។ឥទ្ធិពលដុល្លារកំពុងមានមកលើកម្ពុជាក្រោយពីលំហូរដុល្លារចូលខ្លាំងគ្រាដែលអង្គការសហប្រជាជាតិបានចុះមករៀបចំការបោះឆ្នោតនៅកម្ពុជាកាលពីឆ្នាំ១៩៩៣។នេះបើតាមការលើកឡើងរបស់ស៊ុំសន្និសិទ្ធអគ្គលេខាធិការធនាគារជាតិនៃកម្ពុជា។ ម្យ៉ាងវិញទៀតការធ្លាក់ចុះថ្លៃនូវប្រាក់រៀលក្នុងស្ថានភាពដែលកម្ពុជានិងពិភពលោករងវិបត្តិដោយសារកូវីដ១៩បាននាំឱ្យធនាគារជាតិបានរកវិធីជួយបង្កើនតម្លៃប្រាក់រៀលខ្មែរដោយពិចារណាលើការទទួលក្រដាស់ប្រាក់ដុល្លារប្រភេទតូច។ ធនាគារជាតិកម្ពុជាបានថ្លែងថាគេនឹងបន្តពិភាក្សាជាមួយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដើម្បីឈានទៅកំណត់ ពេលវេលាណាមួយសមស្របដើម្បីការផ្អាកទទួលក្រដាសប្រាក់ដុល្លារអាមេរិកប្រភេទតូចទាំងស្រុងពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុប៉ុន្តែមិនរារាំងហាមឃាត់ការធ្វើចរាចរណ៍ក្រដាសប្រាក់ដុល្លារអាមេរិកប្រភេទតូចទាំងនោះនៅលើទីផ្សារនោះទេ។ បើយើងក្រឡេកមកមើល អាមេរិកជាមហាអំណាចសេដ្ឋកិច្ចពិភពលោក ហើយធនាគារកណ្តាលអាមេរិកជាស្ថាប័នដែលមានសមត្ថភាពខ្ពស់និងដែលគួរឱ្យគេទុកចិត្ត។ ដូច្នេះ បើឱ្យអាមេរិកជាអ្នកចាត់ចែងនយោបាយរូបិយវត្ថុជំនួយធនាគារជាតិកម្ពុជា

វាក៏គួរជារឿងល្អដែរ។ ក៏ប៉ុន្តែគេមិនគួរភ្លេចទេថា ប្រទេសនីមួយៗមានលក្ខណៈពិសេសរៀងៗខ្លួន និងមានស្ថានភាពសេដ្ឋកិច្ចខុសៗគ្នាហើយពេលខ្លះចាំបាច់ត្រូវមាននយោបាយសេដ្ឋកិច្ចខុសគ្នា ដើម្បីឆ្លើយតបទៅនឹងតម្រូវការសេដ្ឋកិច្ចរៀងៗខ្លួន។

ពិតណាស់រូបិយប័ណ្ណជាតិ គឺជានិមិត្តរូបដ៏សំខាន់មួយនៃអធិបតេយ្យជាតិ។ ដូច្នេះ ការចាយលុយរៀល ដែលជារូបិយប័ណ្ណជាតិ និងការគ្រប់គ្រងនយោបាយរូបិយវត្ថុយ៉ាងពេញលេញដោយខ្លួនឯង វាមិនត្រឹមតែផ្តល់ផលប្រយោជន៍ដល់សេដ្ឋកិច្ចជាតិប៉ុណ្ណោះទេ តែវាក៏ជាមោទនភាពរបស់ជាតិខ្មែរទាំងមូលផងដែរ។ ក៏ប៉ុន្តែដើម្បីឱ្យលុយរៀលត្រូវបានគេប្រើប្រាស់ច្រើន និងជាមោទនភាពរបស់ជាតិខ្មែរបាន រដ្ឋាភិបាលកម្ពុជាចាំបាច់ត្រូវតែដាក់ចេញនូវនយោបាយ ដើម្បីស្តារទំនុកចិត្តលើលុយរៀលឡើងវិញ៕

**៣.២.៣ វត្តមាននៃការវិនិយោគពីក្រុមហ៊ុននិងអង្គការក្រៅប្រទេស**

ដុល្លាររូបនីយកម្មក៏មានប្រយោជន៍សំខាន់ៗដែល នៃការចាយលុយដុល្លារគឺវាជួយសម្រួលដល់កម្ពុជាក្នុងការធ្វើសមាហរណកម្ម ក្នុងពាណិជ្ជកម្មអន្តរជាតិ។ ដុល្លារអាមេរិក ដែលជារូបិយប័ណ្ណដ៏មានស្ថិរភាពបានជួយកម្ពុជាឱ្យមានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងបង្កើតបរិយាកាសដែលមានអំណោយផល សម្រាប់ការធ្វើជំនួញ។ ការចាយលុយដុល្លារធ្វើឱ្យអ្នកជំនួញអាចកាត់បន្ថយការចំណាយទៅលើការប្តូរប្រាក់ រវាងលុយរៀល និងលុយដុល្លារ ហើយហានិភ័យនៃអត្រាប្តូរប្រាក់ក៏ត្រូវកាត់បន្ថយច្រើនផងដែរ។ ទាំងនេះគឺជាកត្តាសំខាន់មួយ ដែលជំរុញឱ្យមានវិនិយោគបរទេសនៅក្នុងប្រទេសកម្ពុជា ជាពិសេស នៅក្នុងវិស័យកាត់ដេរ។

កន្លងមក ដុល្លារូបនីយកម្មបានដើរតួនាទីយ៉ាងសំខាន់ក្នុងការស្តារទំនុកចិត្តលើសេដ្ឋកិច្ចរូបិយវត្ថុពីរបបខ្មែរក្រហម។ ឥទ្ធិពលវិជ្ជមាននៃដុល្លារូបនីយកម្មលើស្ថិរភាពសេដ្ឋកិច្ច និងការអភិវឌ្ឍប្រព័ន្ធហិរញ្ញវត្ថុ គឺមានសារៈសំខាន់ចំពោះការពិភាក្សាពាក់ព័ន្ធនឹងបដិដុល្លារូបនីយកម្ម។គួរកត់សម្គាល់ថាប្រតិបត្តិការហិរញ្ញវត្ថុដោយឥតគិតថ្លៃ និងលំហូរចូលទុនវិនិយោគបរទេសនៅក្នុងវិស័យឧស្សាហកម្ម និងទេសចរណ៍បានធ្វើឱ្យកម្រិតដុល្លារូបនីយកម្មមានការកើនឡើង។

- **គ្រប់គ្រងស្ថិរភាពអាត្រាប្តូរប្រាក់** : ដុល្លារូបនីយកម្មទាមទារឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាពិសេសរតនាគារជាតិផ្តល់សាច់ប្រាក់សម្រាប់ចំណាយថវិកាជាប្រាក់រៀល ក្នុងរបៀបមួយដែលអាចធានាស្ថិរភាព អត្រាប្តូរប្រាក់ ។ ដោយសារដុល្លារូបនីយកម្មកាត់បន្ថយសមត្ថភាពរបស់ធនាគារកណ្តាល ក្នុងការប្រើប្រាស់ អត្រាការប្រាក់ដើម្បីគ្រប់គ្រងការផ្គត់ផ្គង់សាច់ប្រាក់ និង តម្លៃនៃរូបិយវត្ថុជាតិ (អត្រាប្តូរប្រាក់) ហេតុដូចនេះហើយ គោលនយោបាយសារពើពន្ធមានតួនាទីសំខាន់ជាងគេ ក្នុងការធានាស្ថេរភាពម៉ាក្រូ សេដ្ឋកិច្ច ។ ការផ្គត់ផ្គង់ប្រាក់រៀលច្រើនពេកទៅក្នុងទីផ្សាររូបិយវត្ថុនឹងប៉ះពាល់ដល់អត្រាប្តូរប្រាក់ភ្លាមៗ ។ យ៉ាងណាក៏ដោយ ដោយសារការប្តូរប្រាក់ដោយសេរីសម្រាប់ប្រតិបត្តិការគណនីចរន្ត និងសេរីភាវូបនីយកម្ម គណនីមូលធន គោលនយោបាយសារពើពន្ធគួរគិតទៅដល់លំហូរចេញ-ចូលនៃសាច់ប្រាក់ជាដុល្លារអាមេរិក តាមរយៈអត្រាប្តូរប្រាក់ ។ ជារួប ក្នុងបរិបទនៃដុល្លារូបនីយកម្ម គោលនយោបាយរូបិយវត្ថុត្រូវបានរៀបចំដើម្បី រក្សាលំនឹងអត្រាប្តូរប្រាក់តាមរយៈការគ្រប់គ្រងថវិកា ដូចជាគោលនយោបាយហិរញ្ញវត្ថុសាធារណៈជាដើម ។ ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចឱ្យបានរឹងមាំក្នុងសេដ្ឋកិច្ចដុល្លារូបនីយកម្មមួយទាមទារឱ្យមានការសហការជិតស្និទ្ធ រវាងធនាគារកណ្តាល និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

- **ជួយរក្សាស្ថិរភាពថ្លៃ**: គោលបំណងមួយនៃគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច គឺធានាស្ថិរភាពថ្លៃ និងកំណើនសេដ្ឋកិច្ច ។ កម្រិតអតិផរណាមានទំនាក់ទំនងយ៉ាងជិតស្និទ្ធនឹងកំណើនសេដ្ឋកិច្ច ។ ក្នុងបរិការណ៍ នៃសេដ្ឋកិច្ចដុល្លារូបនីយកម្ម ស្ថិរភាពថ្លៃអាចសំរេចបានតាមរយៈស្ថិរភាពអត្រាប្តូរប្រាក់ ដោយសារក្នុង ប្រទេសកម្ពុជា ទំនិញប្រើប្រាស់ក្នុងប្រទេសមួយភាគធំនាំចូលពីបរទេស ។ ដូចនេះហើយបម្រែបម្រួល អត្រាប្តូរប្រាក់អាចជះឥទ្ធិពលភ្លាមៗទៅដល់បម្រែបម្រួលថ្លៃ ។ ក្នុងន័យនេះ ការគ្រប់គ្រងថវិកាអាចប្រើជា មធ្យោបាយមួយសម្រាប់ធានាស្ថិរភាពថ្លៃ ។
- **សម្រួលពាណិជ្ជកម្មអន្តរជាតិនិងសមាហរណកម្មសេដ្ឋកិច្ច**: ដុល្លារូបនីយកម្មជួយកាត់បន្ថយចំណាយ ប្រតិបត្តិការ ដែលកើតឡើងមួយផ្នែក ដោយសារភាពខុសគ្នារវាងអត្រាទិញ និងលក់ពេលដូររូបិយវត្ថុជាតិ ទៅរូបិយប័ណ្ណបរទេស ។ កត្តានេះបានរួមចំណែកទៅដល់កំណើនយ៉ាងឆាប់រហ័សនៃវិស័យកាត់ដេរ ។ ការ ការពារហានិភ័យរូបិយប័ណ្ណ ទប់ទល់នឹងដុល្លារអាមេរិកលែងមានភាពចាំបាច់ទៀតហើយ ។ កត្តានេះ នឹងជួយដល់ការធ្វើសមាហរណកម្មទីផ្សារក្នុងស្រុកចូលទៅក្នុងទីផ្សារពិភពលោកទាំងមូល ។ ក្នុងសេដ្ឋកិច្ច ដែលមានកម្រិតដុល្លារូបនីយកម្មខ្ពស់ ទុនបម្រុងអន្តរជាតិប្រើប្រាស់ភាគ គឺប្រើប្រាស់ភាគច្រើន សម្រាប់ធានាបូរណភាពនៃ ប្រព័ន្ធធនាគារ ហើយប្រើបន្ទាប់បន្សំដើម្បីធានាស្ថិរភាពអាត្រាប្តូរប្រាក់ ។ ដូចនេះ ដុល្លារូបនីយកម្មអាចប្រើបាន សម្រាប់ជំរុញការកែលម្អស្ថាប័ន និង គណនេយ្យភាព និងតម្លាភាពហិរញ្ញវត្ថុ ។
- **បាត់បង់កម្រៃបោះផ្សាយក្រដាស់ប្រាក់** : ការខាត់បង់ដ៏សំខាន់នៃដុល្លារូបនីយកម្ម គឺការបាត់បង់កំរៃទទួលបានពីការបោះផ្សាយប្រាក់ ។ ក៏រៃនេះ ជាផលចំណេញកើតមានពីភាពខុសគ្នារវាងចំណាយការបោះពុម្ព និង បែងចែកក្រដាស់ប្រាក់ ទៅនឹងអំណាចទិញនៃក្រដាសប្រាក់ ។ អ្នកខ្លះប៉ាន់ស្មានថា ការបាត់បង់កម្រៃបោះផ្សាយប្រាក់អាចមានចំនួនច្រើនសម្រាប់កម្ពុជា។ ការប៉ាន់ស្មាន ដោយធនាគារជាតិនៃកម្ពុជាចំពោះចំណូលដែលបាត់បង់នេះ ស្ថិតនៅចន្លោះពី ២០ ទៅ ៩០ លានដុល្លារ។

## ៣.៣ ផលប៉ះពាល់ដុល្លារូបនីយកម្មមកលើសេដ្ឋកិច្ចកម្ពុជា

ការចរាចរណ៍រូបិយប័ណ្ណបរទេសត្រូវបានគេសង្កេតឃើញថាមានស្ទើរតែទូទាំងប្រទេសជាពិសេសនៅប្រទេសកម្ពុជា។ ទន្ទឹមនិងការចរាចរណ៍រូបិយប័ណ្ណបរទេសនេះនាំឱ្យមានគុណសម្បត្តិ និង គុណវិបត្តិដល់សេដ្ឋកិច្ចប្រទេសកម្ពុជាដូចខាងក្រោមៈ

### ៣.៣.១ គុណសម្បត្តិ

គុណសម្បត្តិនៃដុល្លារូបនីយកម្ម ក្នុងសេដ្ឋកិច្ចកម្ពុជា

១.រក្សាស្ថេរភាពតម្លៃ

- កាត់បន្ថយអតិផរណា៖ ការប្រើដុល្លារ (ដែលជារូបិយប័ណ្ណខ្លាំង) ជំនួសរូបិយប័ណ្ណជាតិជំរុញឱ្យតម្លៃទំនិញ/សេវាកម្មស្ថិតស្ថេរ។
- ទំនុកចិត្តពីសាធារណៈ៖ ប្រជាពលរដ្ឋ និងអ្នកវិនិយោគមានទំនុកចិត្តលើតម្លៃដុល្លារ ដែលកាត់បន្ថយការទិញបណ្តោះអាសន្ន។

២. កាត់បន្ថយហានិភ័យអត្រាប្តូរប្រាក់

- គ្មានការប្រែប្រួលតម្លៃរូបិយប័ណ្ណ៖ ក្រុមហ៊ុននាំចេញ-នាំចូល និងអ្នកខ្ចីប្រាក់អន្តរជាតិមិនព្រួយបារម្ភពីការធ្លាក់ដុល្លារ។
- គ្រប់គ្រងប្រាក់កម្ចីប្រកបដោយប្រសិទ្ធភាព៖ ការគិតការប្រាក់ និងបំណុលស្ថិតស្ថេរ។

៣. ទាក់ទាញវិនិយោគបរទេស

- ទំនាក់ទំនងសាកល៖ ការប្រើដុល្លារពង្រីកលទ្ធភាពធ្វើជំនួញជាមួយទីផ្សារអន្តរជាតិ។

៤. ប្រសិទ្ធភាពហិរញ្ញវត្ថុ

- ភាពងាយស្រួលធ្វើពាណិជ្ជកម្ម៖ ការទូទាត់អន្តរជាតិមិនទាមទារការប្តូររូបិយប័ណ្ណ។

៥. គ្រប់គ្រងគោលនយោបាយសេដ្ឋកិច្ច

- កាត់បន្ថយគ្រោះមហន្តរាយរបស់រដ្ឋាភិបាល៖ ដុល្លារូបនីយកម្មរាំងការបោះពុម្ពលុយដោយគ្មានការគ្រប់គ្រង (ដែលបង្កអតិផរណា)។

ដោយសារតែមិនមានទំនុកចិត្តលើលុយរៀល អ្នកមានលុយមិនចង់រក្សាទុកលុយរៀលច្រើន ហើយនាំគ្នាស្វះស្វែងរកកន្លែងទុកលុយជាដុល្លារ ឬលុយបរទេសផ្សេងទៀត ដែលគេគិតថាមានហានិភ័យតិចជាង។ ប្រសិនបើនៅកម្ពុជា ដុល្លារមិនត្រូវបានអនុញ្ញាតឱ្យធ្វើចរាចរយ៉ាងទូលំទូលាយដូចសព្វថ្ងៃនេះទេ ដើម្បីអាចទុកលុយជាដុល្លារ គេប្រាកដជាត្រូវយកលុយទៅទុកនៅក្នុងធនាគារឯក្រៅប្រទេស ហើយមូលធនដែលជាកត្តាសំខាន់សំរាប់កំណើនសេដ្ឋកិច្ចជាតិ នឹងត្រូវហូរចេញទៅក្រៅប្រទេស។
ឬក្នុងករណីខ្លះទៀត អ្នកមានលុយ ដែលមិនចង់ទុកជាលុយរៀល ហើយក៏មិនអាចទុកជាដុល្លារនៅក្នុងប្រទេសបាន អាចនាំគ្នាយកលុយទៅទិញមាសទុកជំនួសវិញ។ ការទុកលុយជាមាសនេះ ក៏មិនខុសពីការយកលុយទៅទុកនៅឯធនាគារបរទេសដែរ គឺវានាំឱ្យកម្ពុជាត្រូវបាត់បង់មូលធន សម្រាប់ជំរុញកំណើនសេដ្ឋកិច្ច។ នៅមិនទាន់អស់នៅឡើយទេ នូវគុណសម្បត្តិនៃការប្រើប្រាស់ដុល្លារនៅកម្ពុជា។ ទីមួយគឺពាក់ព័ន្ធនឹងទំនុកចិត្ត នៅពេលដែលសាធារណៈជនមិនមានការទុកចិត្តលើប្រាក់រៀល ការអនុញ្ញាតឱ្យចាយលុយដុល្លារអាចបញ្ចៀសកុំឱ្យកម្ពុជាត្រូវប្រឈមមុខនឹងលំហូរចេញនូវមូលធនទៅក្រៅប្រទេស មានន័យថាដោយសារតែមិនមានទំនុកចិត្តលើប្រាក់រៀល អ្នកមានលុយមិនចង់រក្សាទុកលុយរៀលច្រើន ហើយនាំគ្នាស្វះស្វែងទុកលុយជាដុល្លារឬរូបិយបណ្ណបរទេសផ្សេងៗទៀត ដោយត្រូវយកលុយទៅទុកក្នុងធនាគារនៅក្រៅប្រទេស ហើយមូលធនដែលជាកត្តាសំខាន់សម្រាប់កំណើនសេដ្ឋកិច្ចជាតិនឹងត្រូវហូរចេញទៅក្រៅប្រទេស។ ក្នុងករណីខ្លះទៀតអ្នកមានលុយរៀលនាំគ្នាទៅទិញមាសជំនួសវិញប្រការនេះក៏មិនខុសពីការយកលុយទៅទុកនៅធនាគារបរទេសដែរគឺវានាំឱ្យកម្ពុជាត្រូវបាត់បង់មូលធនសម្រាប់កំណើនសេដ្ឋកិច្ចជាតិ។គុណសម្បត្តិមួយទៀតគឺវាជួយសម្រួលក្នុងការធ្វើសមាហរណកម្មក្នុងពាណិជ្ជកម្មអន្តរជាតិ ដោយហេតុថាវានឹងជួយកាត់បន្ថយឥទ្ធិពលនៃអត្រាប្តូរប្រាក់អន្តរជាតិ ដែលវាជួយជម្រុញឱ្យវិនិយោគិនបរទេសបង្កើនការវិនិយោគនៅក្នុងប្រទេសកម្ពុជាបន្ថែមទៀត។ ទន្ទឹមនឹងគុណសម្បត្តិទាំងនេះដុល្លារូបនីយកម្មក៏មានគុណវិបត្តិផងដែរមកលើប្រទេសកម្ពុជា។

**៣.៣.២ គុណវិបត្តិ**

- បាត់បង់សិទ្ធិក្នុងគោលនយោបាយរូបិយប័ណ្ណកម្ពុជាមិនអាច បោះបង់ប្រាក់ USD ដោយខ្លួនឯងបាននោះទេ ឥទ្ធិពលគ្រប់គ្រងលើសេដ្ឋកិច្ចត្រូវផ្អែកលើសហរដ្ឋអាមេរិក(Fed Policy)

ឧទាហរណ៍៖ ប្រសិនបើ Fed បង្កើនអត្រាការប្រាក់ (interest rate) នាំឱ្យប៉ះពាល់ផ្នែកហិរញ្ញវត្ថុនៅកម្ពុជា

- សេដ្ឋកិច្ចពឹងផ្អែកលើប្រាក់បរទេសការទទួលប្រាក់បញ្ញើ (remittances), ជំនួយ ODA និង FDI បើបន្ថយនាំឱ្យ នឹងប៉ះពាល់ដល់ supply ប្រាក់ USD នៅក្នុងប្រទេស
- រារាំងការអភិវឌ្ឍប្រព័ន្ធសេដ្ឋកិច្ចជាតិបើប្រជាជនពឹង USD ពេកនាំឱ្យ ការជំរុញនិងប្រើប្រាស់ប្រាក់ រៀល នឹងលំបាកនាំឱ្យ កាន់តែប៉ះពាល់ដល់សេវាធនាគារជាតិ (Central Bank Operation)
- ធ្វើឱ្យការប្រមូលពន្ធយឺតយ៉ាវ ឬមិនមានសុវត្ថិភាពប្រសិនបើអាជីវកម្មប្រើប្រាក់ USD ខុសច្បាប់ ឬគ្មានគ្រប់ឯកសារនាំឱ្យ អាចនាំឱ្យបាត់បង់ប្រាក់ពន្ធ (tax leakage)។

គុណវិបត្តិធំជាងគេគឺកម្ពុជាត្រូវបាត់បង់អាវុធដ៏សំខាន់មួយនៅក្នុងនយោបាយម៉ាក្រូសេដ្ឋកិច្ចគឺនយោបាយរូបិយវត្ថុ។ ការចាយលុយដុល្លារអាមេរិកយ៉ាងទូលំទូលាយដូចជាពេលបច្ចុប្បន្ននេះមានន័យថា ទោះចង់មិនចង់មួយផ្នែកធំនៃនយោបាយរូបិយវត្ថុរបស់កម្ពុជាត្រូវបានផ្ទេរទៅឱ្យធនាគារកណ្តាលអាមេរិកជាអ្នកចាត់ចែងជំនួសធនាគារជាតិកម្ពុជាវិញ។ការប្រើប្រាស់ប្រាក់ដុល្លារអាមេរិកដ៏ច្រើនលើសលុបនៅក្នុងប្រព័ន្ធធនាគារបានរារាំងដល់ធនាគារកណ្តាលក្នុងការបន្ទាបអត្រាការប្រាក់ ដើម្បីបង្កើនការវិនិយោគ និងបង្កើតការងារ។ សេដ្ឋកិច្ចកម្ពុជា កំពុងទទួលរងផលប៉ះពាល់ពីដុល្លារូបនីយកម្មទៅលើកត្តាបី យោងតាមប្រសាសន៍របស់លោក គិត សុវណ្ណារិទ្ធ អគ្គនាយករងត្រួតពិនិត្យនៃធនាគារជាតិ នៃកម្ពុជា។

កត្តាទី១ ធនាគារជាតិ នៃកម្ពុជា មានឥទ្ធិពលតិចតួចទៅលើអត្រាការប្រាក់ឥណទានរបស់គ្រឹះស្ថានធនាគារ និងមីក្រូហិរញ្ញវត្ថុ ដោយសារតែ ៨០ភាគរយ នៃប្រាក់បញ្ញើសន្សំ និងកម្ចី ជាប្រាក់ដុល្លារអាមេរិក។ លោកបានបន្តថា យើងមិនអាចប្រើប្រាស់អត្រាការប្រាក់គោលដោយផ្ទាល់ ដើម្បីបង្កើនការងារ និងការវិនិយោគបានទេ។ ធនាគារកណ្តាលភាគច្រើន ដូចជាធនាគារកណ្តាលអាមេរិក មានលទ្ធភាពក្នុងការបញ្ចុះអត្រាការប្រាក់នៃកម្ចីទៅកាន់ធនាគារ ដែលគេឱ្យឈ្មោះថា «អត្រាការប្រាក់គោល»នៅពេលដែលធនាគារកណ្តាលទាំងនោះមានបំណងជំរុញការវិនិយោគ និងបង្កើតការងារ។ ប៉ុន្តែធនាគារជាតិ នៃកម្ពុជា អាចមានលទ្ធភាពត្រឹមបញ្ចុះអត្រាការប្រាក់គោលនៃប្រាក់រៀលប៉ុណ្ណោះ។ផលប៉ះពាល់នៃដុល្លាររូបនីយកម្ម (The advantages and disadvantages of Dollarization) ជាការពិតណាស់ការរក្សាទុក និងការចាយវាយដុល្លារដូចនេះ គឺជាមធ្យោបាយមួយរបស់និវាសនជនកម្ពុជាក្នុងការថែរក្សាតម្លៃនៃប្រាក់សន្សំរបស់ខ្លួនឱ្យបានគង់វង្សល្អ និងមានប្រសិទ្ធភាពព្រោះលុយដុល្លារមានស្ថេរភាពជាងលុយរៀល។តែការអនុវត្តន៍នេះមានគុណវិបត្តិជាច្រើននិងគុណសម្បត្តិខ្លះៗដូចគ្នា។ដុល្លាររូបនីយកម្មបានលេចចេញជាឯកច្ឆន្ទនៅក្នុងប្រទេសកម្ពុជា ដោយសារតែទំនុកចិត្តរបស់សាធារណជនលើប្រាក់រៀលបានធ្លាក់ចុះបន្ទាប់ពីមានវិបត្តិជាបន្តបន្ទាប់ដែលរាប់ចាប់ពីការបំផ្លាញហេដ្ឋារចនាសម្ព័ន្ធទាំងអស់របស់ពួកខ្មែរក្រហម រហូតដល់ការគ្រប់គ្រងមិនត្រឹមត្រូវនៃសេដ្ឋកិច្ច។ កង្វះទំនុកចិត្តរបស់សាធារណជនចំពោះស្ថាប័ន និងប្រព័ន្ធធនាគារនៅតែមានកំរិតខ្ពស់ ហើយការធ្វើដុល្លាររូបនីយកម្មនៅតែបន្តដំណើរការទោះបីជាមានភាពប្រសើរឡើងនាពេលថ្មីៗនេះចំពោះស្ថេរភាពម៉ាក្រូសេដ្ឋកិច្ចនិងវិធានការណ៍របស់អាជ្ញាធរដើម្បីស្តារទំនុកចិត្តឡើងវិញក៏ដោយ។មិនគួរចាត់វិធានការដ៏ឃោរឃៅណាមួយដើម្បីប្រឆាំងនឹងការប្រើប្រាស់ប្រាក់ដុល្លារឡើយ។ទោះយ៉ាងណាក៏ដោយវាចាំបាច់

ក្នុងការបង្កើន និងជំរុញអោយមានការប្រើប្រាស់រូបិយប័ណ្ណជាតិ។នៅក្នុងការផុសបន្ទាប់យើងនឹងធ្វើការបកស្រាយពីផលវិជ្ជមាន និងអវិជ្ជមាននៃការប្រើប្រាស់ប្រាក់ដុល្លារអាមេរិកនៅក្នុងសេដ្ឋកិច្ចកម្ពុជា។

កត្តាទី២ ការបាត់បង់ចំណូលពីការបោះពុម្ពក្រដាសប្រាក់(ផលសងរវាងថ្លៃដើមនៃការផលិត និងតម្លៃចារិកនៃក្រដាសប្រាក់ដែលត្រូវបានបោះពុម្ព)។យោងតាមការសិក្សារបស់មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF)ការខាតបង់ចំណូលពីការបោះពុម្ពក្រដាសប្រាក់ គឺស្មើនឹង ១០ភាគរយ នៃផលិតផលក្នុងស្រុកសរុប។ ប្រសិនបើមិនមានការខាតបង់ចំណូលនេះទេ ថវិកាដែលបានពីចំណូលនេះអាចត្រូវបានផ្តល់ជាហិរញ្ញប្បទានដល់ការកសាងហេដ្ឋារចនាសម្ព័ន្ធនិងគម្រោងអភិវឌ្ឍន៍សង្គម។

កត្តាទី៣ ដុល្លារូបនីយកម្មបានរាំងដល់ធនាគារជាតិ នៃកម្ពុជា ក្នុងការអនុវត្តគោលនយោបាយរូបិយវត្ថុឱ្យបានពេញលេញ។ គួរបញ្ជាក់ផងដែរថា ពាក្យថា ដុល្លារនីយកម្មនេះ មិនមែនសំដៅតែការប្រើប្រាស់ប្រាក់ដុល្លារអាមេរិកក្រៅទឹកដីអាមេរិកប៉ុណ្ណោះនោះទេ តែក៏សម្រាប់រូបិយបណ្ណបរទេសណាដែលត្រូវបានគេប្រើប្រាស់នៅក្រៅទឹកដីរបស់ខ្លួនផងដែរ។

# ជំពូកទី៤
# ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

# ជំពូកទី៤
# ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

## ៤.១ ការវិភាគលើចំណុចខ្លាំង

- ប្រាក់ដុល្លារអនុញ្ញាតអោយប្រជាពលរដ្ឋអាចរក្សាបាននូវអំណាចទិញរបស់ខ្លួន។ ជាឧទាហរណ៍ ក្នុងពេលនៃកើនឡើងនូវវិបត្តិអាស៊ីជាដើមរូបបិយវត្ថុស្ទើតែទាំងអស់ ត្រូវបានធ្លាក់ចុះតម្លៃជាខ្លាំងធៀបនឹងប្រាក់ដុល្លារអាមេរិក។
- ដុល្លារូបនីយកម្ម ជាប្រាំងទប់ហិរញ្ញប្បទានរូបិយវត្ថុជាតិចំពោះតម្រូវការរដ្ឋ។ ព្រោះថាហិរញ្ញប្បទានបែបនេះក្នុងខណៈដែលមិនមានការទុកចិត្តពីភ្នាក់ងារសេដ្ឋកិច្ច អាចបណ្តាលអោយមានការយកប្រាក់រៀលទៅទិញដុល្លារអាមេរិកទុក ជាហេតុធ្វើអោយប្រាក់រៀលមានការថមថយតម្លៃ។
- ប្រាក់ដុល្លារបានជួយសម្រួលដល់ការទូទាត់ផ្ទាល់ចំពោះការទិញទំនិញ និងសេវាដែលមានតម្លៃខ្ពស់នៅពេលដែលក្រដាសប្រាករៀលមានតែប្រភេទតូច ( នៅពេលដែលប្រទេសយើងមានតែក្រដាល ៥០០រៀលមុនឆ្នាំ ១៩៩៥)។
- វាជួយបង្វែរចំណូលចិត្តរបស់សាធារណៈជនពីការប្រើប្រាស់មាស មកជាការប្រើប្រាស់ក្រដាសប្រាក់វិញ (ប្រាក់ដុល្លារ និងប្រាក់បាត) ក្នុងខណៈដែលប្រាក់រៀលមិនទាន់ត្រូវបានទូទាត់អោយបានទូលំទូលាយនៅឡើយ បណ្តាលមកពីមហាជនគ្មានជំនឿទុកចិត្ត និងដោយត្រូវការក្រដាសប្រាក់ច្រើនពេកក្នុងការទូទាត់ម្តងៗ។
- គុណប្រយោជន៍ គឺនៅត្រង់ថា នៅក្នុងពេលដែលសាធារណជនមិនមានទំនុកចិត្តលើលុយរៀល ការអនុញ្ញាតឱ្យចាយលុយដុល្លារ អាចបញ្ចៀសកុំឱ្យកម្ពុជាត្រូវប្រឈមមុខនឹងចលនាហូរចេញមូលធនទៅក្រៅប្រទេស។ ដោយសារតែមិនមានទំនុកចិត្តលើលុយរៀល អ្នកមានលុយមិនចង់រក្សាទុកលុយរៀលច្រើន ហើយនាំគ្នាស្វះស្វែងរកកន្លែងទុកលុយជាដុល្លារ ឬលុយបរទេសផ្សេងទៀត ដែលគេគិតថាមានហានិភ័យតិចជាង។ ប្រសិនបើនៅកម្ពុជា ដុល្លារមិនត្រូវបានអនុញ្ញាតឱ្យធ្វើចរាចរយ៉ាងទូលំទូលាយដូចសព្វថ្ងៃនេះទេ ដើម្បីអាចទុកលុយជាដុល្លារ គេប្រាកដជាត្រូវយកលុយទៅទុកនៅក្នុងធនាគារឯក្រៅប្រទេស ហើយមូលធនដែលជាកត្តាសំខាន់សំរាប់កំណើនសេដ្ឋកិច្ចជាតិ នឹងត្រូវហូរចេញទៅក្រៅប្រទេស។

## ៤.២ ការវិភាគលើចំណុចខ្សោយ

ទន្ទឹមនឹងគុណប្រយោជន៍ទាំងអស់នេះ ការចាយលុយដុល្លារក៏មានគុណវិបត្តិច្រើនផងដែរ។ គុណវិបត្តិធំជាងគេ គឺកម្ពុជាត្រូវបាត់បង់អាវុធដ៏សំខាន់មួយនៅក្នុងនយោបាយម៉ាក្រូសេដ្ឋកិច្ច គឺនយោបាយរូបិប័ណ្ណ។ ការចាយលុយដុល្លារអាមេរិកយ៉ាងទូលំទូលាយដូចជាពេលបច្ចុប្បន្ននេះ មានន័យថាទោះចង់មិនចង់ មួយផ្នែកធំនៃនយោបាយរូបិយវត្ថុរបស់កម្ពុជាត្រូវបានផ្ទេរទៅធនាគារកណ្តាលអាមេរិកជាអ្នកចាត់ចែងជំនួសធនាគារជាតិកម្ពុជាវិញ។ ជាការពិតណាស់ការរក្សាទុក និងការចាយវាយដុល្លារដូចនេះ គឺជាមធ្យោបាយមួយរបស់និវាសនជនកម្ពុជាក្នុងការថែរក្សាតម្លៃនៃប្រាក់សន្សំរបស់ខ្លួនអោយបានគង់វង្សល្អ និងមានប្រសិទ្ធភាពព្រោះលុយដុល្លារមានស្ថេរភាពជាងលុយរៀល។ តែការអនុវត្តន៍នេះមានគុណវិបត្តិជាច្រើន និងគុណសម្បត្តិខ្លះៗដូចគ្នា។

ដុល្លារូបនីយកម្មបានលេចចេញជាឯកច្ឆន្ទនៅក្នុងប្រទេសកម្ពុជា  ដោយសារតែទំនុកចិត្តរបស់សាធារណជនលើប្រាក់រៀលបានធ្លាក់ចុះបន្ទាប់ពីមានវិបត្តិជាបន្តបន្ទាប់ដែលរាប់ចាប់ពីការបំផ្លាញហេដ្ឋារចនាសម្ព័ន្ធទាំងអស់របស់ពួកខ្មែរក្រហម រហូតដល់ការគ្រប់គ្រងមិនត្រឹមត្រូវនៃសេដ្ឋកិច្ច។ កង្វះទំនុកចិត្តរបស់សាធារណជនចំពោះស្ថាប័ននិងប្រព័ន្ធធនាគារនៅតែមានកំរិតខ្ពស់ហើយការធ្វើដុល្លារូបនីយកម្មនៅតែបន្តដំណើរការទោះបីជាមានភាពប្រសើរឡើងនាពេលថ្មីៗនេះចំពោះស្ថេរភាពម៉ាក្រូសេដ្ឋកិច្ចនិងវិធានការណ៍របស់អាជ្ញាធរដើម្បីស្តារទំនុកចិត្តឡើងវិញក៏ដោយ។ មិនគួរចាត់វិធានការដ៏ឃោរឃៅណាមួយដើម្បីប្រឆាំងនឹងការប្រើប្រាស់ប្រាក់ដុល្លារឡើយ។ ទោះយ៉ាងណាក៏ដោយវាចាំបាច់ក្នុងការបង្កើន និងជំរុញអោយមានការប្រើប្រាស់រូបិយប័ណ្ណជាតិ។

មិនតែប៉ុណ្ណោះចំណុចខ្សោយមានជាច្រើនដូចជា៖

- ដុល្លារូបនីយកម្មធ្វើឱ្យកម្ពុជាខាតបង់ប្រាក់ចំណូលពីការបោះពុម្ពក្រដាសប្រាក់។ នៅពេលមានការប្រើប្រាស់រូបិវត្ថុជាតិកាន់តែច្រើនរដ្ឋាភិបាលនិង ទទួលបានប្រាក់ចំណូល កាន់តែច្រើនផងដែរ។
- ការប្រើប្រាស់ប្រាក់ដុល្លារអាចធ្វើឱ្យបាត់បង់អត្តសញ្ញាណជាតិ។ រូបិយវត្ថុជាតិដើរតួនាទីជាអង្គ សញ្ញាណជាតិមួយតំណាងឱ្យប្រជាជននិងប្រទេសជាតិ។ ហេតុនេះការប្រើប្រាស់រូបិយវត្ថុពិតជា សាមគ្គីភាពក្នុងចំណោមប្រជាជននៃសង្គមមួយ។
- ដុល្លារូបនីយកម្ម បានដាក់កំហិតដល់ជម្រើសឧបករណ៍និងប្រសិទ្ធភាពនៃគោលនយោបាយសេដ្ឋកិច្ច។ ការប្រើប្រាស់រូបិយវត្ថុកាន់តែទូលំទូលាយនៅគ្រប់វិស័យទាំងអស់និងផ្តល់លទ្ធភាព ឱ្យរដ្ឋាភិបាលពង្រឹងការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចដើម្បីជំរុញ និង រក្សានិរន្តភាពកំណើនដោយសារបរិមាណផ្គត់ផ្គង់រូបិយវត្ថុមានឥទ្ធិពលដោយផ្ទាល់ទៅលើសេដ្ឋកិច្ច(ផលិតកម្មនិងការងារ)។
- ទំហំនៃដុល្លារូបនីយកម្មនាពេលនោះ ធ្វើឱ្យប៉ះពាល់ដល់ការអនុវត្តគោលនយោបាយរូបិយវត្ថុ(Monetary Policy) អោយមានប្រសិទ្ធភាព និងហួសពីការគ្រប់គ្រងរបស់ធនាគារជាតិហើយក្នុងនាមជាអ្នកផ្តល់កម្ចីចុងក្រោយ(Lender of last Resort) ក៏បានប្រឈមនិងបញ្ហាសាច់ប្រាក់យ៉ាងខ្លាំង។
- ការប្រើប្រាស់លុយដុល្លារច្រើន ធ្វើឱ្យរូបិយប័ណ្ណជាតិធ្លាក់តម្លៃ ហើយបាត់បង់ភាពជានិមិត្តរូបនៃអធិបតេយ្យភាពនិងជាតិសាសន៍។

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ៥.១ សេចក្តីសន្និដ្ឋាន

ឆ្លងតាមរយៈការសិក្សាស្រាវជ្រាវនិងវិភាគទៅលើប្រធានបទ( ផលប៉ះពាល់ដុល្លារូបនីយកម្មមកលើសេដ្ឋកិច្ចកម្ពុជា )រួចមកក្រុមរបស់យើងខ្ញុំអាចយល់ថាការប្រើប្រាស់ដុល្លាររូបនីយកម្មនៅក្នុងសេដ្ឋកិច្ចកម្ពុជាមានការហូរចូលយ៉ាងច្រើនជាបន្តបន្ទាប់ដោយសារការបើកចំហរសេដ្ឋកិច្ចដែលអនុញ្ញាតឱ្យមានលំហរវិនិយោគដើមទុនជាប្រាក់ដុល្លារអាមេរិកចូលមកកម្ពុជា។ ភាពទន់ខ្សោយនៃគោលការនយោបាយរាជរដ្ឋាភិបាលនិងធនាគារកណ្តាលបានធ្វើឱ្យប្រជាពលរដ្ឋបាត់បង់ជំនឿទុកចិត្តលើប្រាក់រៀលនៅលើទីផ្សារក៏បានធ្លាក់ចុះដាលំដាប់ដែលនាំឱ្យពួកគេងាកមករកប្រាក់ដុល្លារអាមេរិកដើម្បីបំពេញនូវតម្រូវការរបស់ពួកគេ។

ដុល្លារូបនីយកម្មបាននាំមកនូវទាំងផលប្រយោជន៍និងហានិភ័យចំពោះកម្ពុជា។ចំពោះអត្ថប្រយោជន៍ដុល្លារូបនីយកម្មបានរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចនិងប្រព័ន្ធហិរញ្ញវត្ថុកម្ពុជាហើយបានបង្កើនសមាហរណកម្មសេដ្ឋកិច្ចកម្ពុជាទៅក្នុងតំបន់និងអន្តរជាតិក្នុងពេលដែលកម្រិតសមាហរណកម្មកម្ពុជានៅមានកម្រិតដ៏ទាបនៅឡើយនាអំឡុងពេលដែរសេដ្ឋកិច្ចកំពុងចាប់ផ្តើមលូតលាស់។ផលប្រយោជន៍ទាំងនោះត្រូវបានឆ្លុះបញ្ចាំងក្នុងរូបភាព៖ ការកាត់បន្ថយថ្លៃដើមនៃដើមទុនសម្រាប់ការវិនិយោគ ការជួយអភិវឌ្ឍវិស័យហិរញ្ញវត្ថុពេលដែលប្រជាជនកម្ពុជាបានបាត់បង់ជំនឿទុកចិត្តមកលើប្រព័ន្ធហិរញ្ញវត្ថុ និងការបង្កើននិន័យវិស័យសារពើពន្ធការសម្រួលការទូទាត់ពាណិជ្ជកម្មអន្តរជាតិការទាក់ទាញការវិនិយោគពីបរទេសកម្រិតទាបនៃអតិផរណាំស្ថិរភាពអត្រាប្តូរប្រាក់និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចហើយដុល្លាររូបនីយកម្មបានជួយស្តារស្ថានភាពម៉ាក្រូសេដ្ឋកិច្ចឱ្យប្រសើរឡើងវិញ។ នៅពេលដែលសេដ្ឋកិច្ចប្រទេសកម្ពុជាកាន់តែមានការរីកចម្រើននិងប្រទាក់ក្រឡាដុល្លាររូបនីយកម្មមិនត្រឹមតែធ្វើឱ្យកម្ពុជាខាតបង់ចំណូលពីការបោះពុម្ពក្រដាសប្រាក់រៀលប៉ុណ្ណោះទេថែមទាំងអាចបង្កជាហានិភ័យ និងមានគុណវិបត្តិកាន់តែច្រើនចំពោះសេដ្ឋកិច្ចកម្ពុជាជាពិសេសធ្វើឱ្យមានភាពផុយស្រួយទៅនឹងការប៉ះទង្គិចទាំងកត្តាក្នុងស្រុកនិងខាងក្រៅ។ ម្យ៉ាងទៀតដុល្លាររូបនីយកម្មបានក្លាយជាឧបសគ្គមួយក្នុងការជំរុញសមាហរណកម្មក្នុងតំបន់ផងដែរនៅក្នុងក្របខ័ណ្ឌសហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC) ដែលប្រទេសនីមួយៗខិតខំប្រើប្រាស់រូបិយវត្ថុផ្ទាល់ខ្លួនក្នុងប្រតិបត្តិការសេដ្ឋកិច្ចតំបន់ដោយកាត់បន្ថយការរំពឹងផ្អែកលើប្រាក់ដុល្លារអាមេរិក។លើសពីនេះការប្រើប្រាស់ប្រាក់ដុល្លារអាមេរិកបានបង្កជាការលំបាកខ្លាំងដល់ការអនុវត្តគោលនយោបាយរូបិយវត្ថុដោយវាបានកាត់បន្ថយប្រសិទ្ធភាពគោលនយោបាយ និងរារាំងដល់ការប្រើប្រាស់ឧបករណ៍គោលនយោបាយរូបិយវត្ថុដូចជាអត្រាការប្រាក់ជាដើម។ជាងនេះទៅទៀតដោយរូបិយវត្ថុជាតិតំណាងឱ្យអត្តសញ្ញាណ វប្បធម៌ សាសនា និងប្រវត្តិសាស្ត្ររបស់ជាតិយើងការប្រើប្រាស់ប្រាក់ដុល្លារអាមេរិក និងការមិនចូលរួមប្រើប្រាស់រូបិយវត្ថុរបស់ជាតិយើង គឺមានន័យថាមិនបានចូលរួមលើកស្ទួយដល់អត្តសញ្ញាណជាតិរបស់យើង។

សរុបមកយោងតាមការសិក្សាស្រាវជ្រាវ និងពិភាក្សាគ្នាយ៉ាងសកម្មនៃសារណារបស់ក្រុមយើងខ្ញុំទៅលើប្រធានបទ“**ផលប៉ះពាល់ដុល្លារូបនីយកម្មមកលើសេដ្ឋកិច្ចកម្ពុជា**”រួចមកក្រុមរបស់យើងខ្ញុំអាចសន្និដ្ឋានបានថាដុល្លារូបនីយកម្មបានផ្តល់នូវអត្ថប្រយោជន៍ដល់សេដ្ឋកិច្ចកម្ពុជានៅក្នុងដំណាក់កាលដែលកម្ពុជាកំពុងអភិវឌ្ឍសេដ្ឋកិច្ចនៅក្នុងរយៈពេលវែង នៅពេលដែលសេដ្ឋកិច្ចកម្ពុជាចាប់ផ្តើមមានការរីកចម្រើនជឿនលឿននិងមាន

ទំហំកាន់តែធំដុល្លារូបិយកម្ម និងរារាំងដល់ការអនុវត្តគោលនយោបាយរូបិយវត្ថុដើម្បីការពារប្រព័ន្ធហិរញ្ញវត្ថុ សេដ្ឋកិច្ចកម្ពុជាពីវិបត្តិហានិភ័យ និងបញ្ហាប្រឈមដែលបណ្ដាលមកពីកត្តាខាងក្នុង និងខាងក្រៅ។ ដូចនេះដើម្បី បន្តជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយភាពប្រុងប្រយ័ត្ននិងហានិភ័យទាបព្រមទាំងដើម្បីលើកស្ទួយដល់អត្ត សញ្ញាណជាតិ យើងប្រជាពលរដ្ឋខ្មែរទាំងអស់គួរចាប់ផ្ដើមងាកមកប្រើប្រាស់រូបិយវត្ថុជាតិ "ប្រាក់រៀល" និងកាត់ បន្ថយការប្រើប្រាស់ប្រាក់ដុល្លារអាមេរិកបន្តិចម្តងៗ។

## ៥.២ ការផ្ដល់អនុសាសន៍

- ដុល្លារូបនីយកម្មធ្វើឱ្យកម្ពុជាខាតបង់ប្រាក់ចំណូលពីការបោះពុម្ពក្រដាសប្រាក់។ នៅពេលមានការប្រើ ប្រាស់រូបិវត្ថុជាតិកាន់តែច្រើនរដ្ឋាភិបាលនិង ទទួលបានប្រាក់ចំណូល កាន់តែច្រើនផងដែរ។
- ការប្រើប្រាស់ប្រាក់ដុល្លារអាចធ្វើឱ្យបាត់បង់អត្តសញ្ញាណជាតិ។ រូបិយវត្ថុជាតិដើរតួនាទីជាអង្គ សញ្ញាណ ជាតិមួយតំណាងឱ្យប្រជាជននិងប្រទេសជាតិ។ ហេតុនេះការប្រើប្រាស់រូបិយវត្ថុពិតជា សាមគ្គីភាពក្នុងចំ ណោមប្រជាជននៃសង្គមមួយ។
- ដុល្លារូបនីយកម្ម បានដាក់កំហិតដល់ជម្រើសឧបករណ៍និងប្រសិទ្ធភាពនៃគោលនយោបាយសេដ្ឋកិច្ច។ ការប្រើប្រាស់រូបិយវត្ថុកាន់តែទូលំទូលាយនៅគ្រប់វិស័យទាំងអស់និងផ្ដល់លទ្ធភាព ឱ្យរដ្ឋាភិបាលពង្រឹង ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចដើម្បីជំរុញ និង រក្សានិរន្តភាពកំណើនដោយសារបរិមាណផ្គត់ផ្គង់រូបិយវត្ថុ មានឥទ្ធិពលដោយផ្ទាល់ទៅលើសេដ្ឋកិច្ច(ផលិតកម្មនិងការងារ)។
- ទំហំនៃដុល្លារូបនីយកម្មនាពេលនោះ ធ្វើឱ្យប៉ះពាល់ដល់ការអនុវត្តគោលនយោបាយរូបិយវត្ថុ(Monetary Policy) អោយមានប្រសិទ្ធភាព និងហួសពីការគ្រប់គ្រងរបស់ធនាគារជាតិហើយក្នុងនាមជាអ្នកផ្ដល់កម្ចី ចុងក្រោយ(Lender of last Resort) ក៏បានប្រឈមនិងបញ្ហាសាច់ប្រាក់យ៉ាងខ្លាំង។
- ការប្រើប្រាស់លុយដុល្លារច្រើន ធ្វើឱ្យរូបិយប័ណ្ណជាតិធ្លាក់តម្លៃ ហើយបាត់បង់ភាពជានិមិត្តរូបនៃ អធិបតេយ្យភាពនិងជាតិសាសន៍។

ដើម្បីធ្វើបដិដុល្លារូបនីយកម្មជាសន្សឹមៗប្រកបដោយភាពប្រុងប្រយ័ត្ន និងហានិភ័យទាប គោល នយោបាយនិងវិធានការគាំទ្រការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល គួរត្រូវបានដាក់ចេញ ដោយស្របតាម គោលការណ៍យន្តការទីផ្សារ រួមមាន៖ ១/- ការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងជំនឿ ទុកចិត្តមកលើប្រាក់រៀល តាមរយៈការរក្សាស្ថិរភាពថ្លៃ និងតម្លៃប្រាក់រៀល ដើម្បីការពារអំណាចទិញរបស់ប្រាក់រៀល ២/- ការពង្រឹងគុណ ភាព និងសោភ័ណភាពក្រដាសប្រាក់រៀលឱ្យកាន់តែមានភាព ទាក់ទាញ ពិបាកក្នុងការក្លែងបន្លំ ស្អាត និងងាយ ស្រួលកាន់ ៣/- ការបំពេញតម្រូវការប្រាក់រៀល របស់សេដ្ឋកិច្ចតាមរយៈការចាក់បញ្ចូលសន្ទនីយភាពជាប្រាក់ រៀលចូលទៅក្នុងសេដ្ឋកិច្ច ៤- ការលើក ទឹកចិត្ត និងជំរុញឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ក៏ដូចជាសាធារណ ជននានាប្រើប្រាស់ប្រាក់រៀល ដូចជាការដំឡើងសន្សឹមៗនូវអត្រាប្រាក់បម្រុងកាតព្វកិច្ចលើប្រាក់បញ្ញើនិងកម្ចី (Borrowings) ជាប្រាក់ដុល្លារអាមេរិក ការកាត់បន្ថយជាបណ្ដើរៗទៅលើអត្រាការប្រាក់ឥណទានជាប្រាក់រៀល និង ការយកកម្រៃសេវាផ្សេងៗជាប្រាក់រៀលទាបជាងរូបិយប័ណ្ណ ៥/- តម្រូវឱ្យការបង់ពន្ធ និងការបង់ថ្លៃ សេវា

សាធារណៈផ្សេងៗជាប្រាក់រៀល ៦/- ការផ្សព្វផ្សាយនិងអប់រំពីសារៈសំខាន់នៃរូបិយវត្ថុជាតិ ចំពោះសេដ្ឋកិច្ចនិងប្រទេសជាតិទៅដល់សាធារណជន និងកូនចៅជំនាន់ក្រោយឱ្យយល់ដឹងកាន់តែ ច្បាស់ និង ៧/- ការលើកទឹកចិត្តឱ្យអាជីវករកំណត់ថ្លៃទំនិញ និងសេវាជាប្រាក់រៀលដែរ។

# ឯកសារយោង


1. Cambonomic. Times. (30-ឧសភា-2020). *តើអ្វីជាដុល្លាររូបនីយកម្ម?* Retrieved September, 9 2025 from https://www.facebook.com/CambonomicTimes/posts/តើអ្វីជាដុល្លាររូបនីយកម្មដុល្លាររូបនីយកម្ម-គឺសំដៅដល់បាតុភូតដែលប្រជាពលរដ្ឋនៃប្រទេសម/138464247814397/
2. សេដ្ឋកិច្ច. (2019, November 28). *តើដុល្លាររូបនីយកម្មគឺជាអ្វី?* Retrieved September, 9 2025 from https://www.khsearch.com/qna/27047
3. កម្ពុជាថ្មី. (2023, June 19). *តើអ្វីជាដុល្លាររូបនីយកម្ម?* Retrieved September, 9 2025 from https://www.kampucheathmey.com/business-economic/529638
4. Khmer Time. (2024, March 25 ). *"ដុល្លាររូបនីយកម្មឬបដិដុល្លាររូបនីយកម្ម"*. Retrieved September, 10 2025 from https://www.khmertimeskh.com/501258485
5. University at Buffalo. (2024). *"Economic"*. Retrieved September, 10 2025 from https://arts-sciences.buffalo.edu/economics/about/ what-is-economics.html
6. KHsearch. សេដ្ឋកិច្ច. (2019, January 19). *តើសេដ្ឋកិច្ចគឺជាអ្វី?*. Retrieved September, 10 2025 from https://www.khsearch.com/qna/2013654
7. Econlib. (2018, February 05). *និយមន័យសេដ្ឋកិច្ច*. Retrieved September, 10 2025 from https://www.econlib.org/library/Topics/College/ whatiseconomics.html
8. Robbins, L. C. (1932). *An Essay on the Nature and Significance of Economic*
9. London School of Economics. (1971). *"ប្រវត្តិសេដ្ឋកិច្ច"*. Retrieved September, 10 2025 from https://en.m.wikipedia.org/wiki/ Economic_history
10. WIKIPEDIA. *ទ្រឹស្តីនៃសេដ្ឋកិច្ច*. Retrieved October, 10 2025 from https://en.m.wikipedia.org/wiki/Economic_history
11. SplashLearn. (dollar). *និយមន័យដុល្លារ*. Retrieved October, 10 2025 from https://www.splashlearn.com/math-vocabulary/money/
12. AMS. (2023, June 04). *និយមន័យដុល្លារ*. Retrieved October, 10 2025 from https://economy.ams.com.kh/
13. Wikipedia. SplashLearn. *និយមន័យដុល្លារ*. Retrieved October, 1 2025 from https://en.m.wikipedia.org/wiki/
14. **ស្រ៊ុន សុខខុន**. (2023, December 11) កម្មវិធីប្រកួតប្រជែងស្នាដៃស្រាវជ្រាវរដូវកាលទី៥ *"ឥទ្ធិពលនៃដុល្លាររូបនីយកម្មមកលើសេដ្ឋកិច្ចកម្ពុជា"* នៃសាកលវិទ្យាល័យវ៉ាន់ដា ទំព័រទី៤៣ នៃទំព័រ៤៥។
15. http://elibrary-rule.com/theses/245
16. Sabay. ប៊ិន ប៊ុណ្ណា. (2016, March 22). *ដឹងថាហេតុអ្វីបានជាប្រាក់រៀលបាត់ទំនុកចិត្តនៅលើទីផ្សារទេ?* February, 2 2025 https://news.sabay.com.kh/article/657183
17. RFI. (2014, March 31). *"ផលប៉ះពាល់ដុល្លាររូបនីយកម្មមកលើសេដ្ឋកិច្ចកម្ពុជា"* Retrieved February, 2 2025 from https://www.rfi.fr/km/cambodia/20140331-how-effective-of-using-dollar-currency-in-cambodia
18. Khmer Times. (2017, March 13). *គុណសម្បត្តិ និងគុណវិបត្តនៃដុល្លាររូបនីយកម្ម*. Retrieved February, 3 2025 From https://www.khmertimeskh.com/14417

# ឧបសម្ព័ន្ធ


កម្មវិធីប្រកួតប្រជែងស្នាដៃស្រាវជ្រាវ
រដូវកាលទី ៥
016.244
ស្រ៊ិន សុខខុន
VIA.PP/2023
ប្រធានបទ៖
“ឥទ្ធិពលនៃដុល្លារូបនីយកម្មមកលើសេដ្ឋកិច្ចកម្ពុជា”


១០០០០០
100000
DOLLARS


100


ធនាគារជាតិ នៃ កម្ពុជា
NATIONAL BANK OF CAMBODIA
Riel. Stability. Development.

